**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងការទទួលខុសត្រូវខ្ពស់ចំពោះសុខុមាលភាព បរិស្ថាននិងសង្គម ក្នុងប្រតិបត្តិការធនធានរ៉ែ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី៖

ក- ការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

ខ- ការគ្រប់គ្រងនិងការប្រើប្រាស់ដី ក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

គ- នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

ឃ- សិទ្ធិនិងកាតព្វកិច្ចរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ ក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពស្វែងរុករកនិងឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្រោមអាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យសព្ទសំខាន់ៗប្រើក្នុងអនុក្រឹត្យនេះមានន័យដូចខាងក្រោម៖

ការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ សំដៅដល់ការផ្ទេរសិទ្ធិ ឬការលក់ភាគហ៊ុន ឬការបង្កើតសម្ពន្ធអាជីវកម្ម ឬការចងសម្ពន្ធភាពឬដៃគូធុរកិច្ច ឬការផ្ទេរផលប្រយោជន៍ឬចំណែកណាមួយនៃផលប្រយោជន៍ ឬការចុះកិច្ចព្រមព្រៀងធុរកិច្ចផ្សេងៗពាក់ព័ន្ធនឹងការផ្ទេរផលប្រយោជន៍នៅក្នុងអាជ្ញាបណ្ណដែលធ្វើឡើងស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

បុគ្គលពាក់ព័ន្ធជាមួយនឹងសម្បទានិកដែលមានអាជ្ញាបណ្ណ សំដៅដល់បុគ្គលណាមួយដូចខាងក្រោម៖

- តំណាងរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ
- បុគ្គលដែលមានភាគហ៊ុនឬដែលមានផលប្រយោជន៍ពាក់ព័ន្ធជាមួយនឹងសម្បទានិកដែលមានអាជ្ញាបណ្ណ
- តំណាងរបស់បុគ្គលដែលមានភាគហ៊ុនឬតំណាងរបស់បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធជាមួយនឹងសម្បទានិកដែលមានអាជ្ញាបណ្ណ។

ការរៀបចំនិងការអភិវឌ្ឍអាជីវកម្មធនធានរ៉ែ សំដៅដល់ការសាងសង់បង្កើតផ្លូវចេញ ចូល ផ្លូវដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ ឬមធ្យោបាយផ្សេងៗ ក្នុងគោលបំណងជីកយក ចម្រាញ់ បន្សុទ្ធ ធ្វើប្រព្រឹត្តិកម្ម កែច្នៃ ផលិតកម្ម ស្តុកទុក ដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មផលិតផលរ៉ែ។

ការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ សំដៅដល់សកម្មភាពនានាដើម្បីបញ្ចប់ប្រតិបត្តិការធនធានរ៉ែរួមបញ្ចូលទាំងការស្តារបរិស្ថាន ក្នុងគោលបំណងសម្អាតកែលម្អការដ្ឋាននិងស្តារបរិស្ថានឡើងវិញ

នៅតាមទីតាំងដែលមានផលប៉ះពាល់ឬខូចខាត បណ្តាលមកពីប្រតិបត្តិការធនធានរ៉ែក្រោមការត្រួតពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថាន។

កាតព្វកិច្ចហិរញ្ញវត្ថុ សំដៅដល់កាតព្វកិច្ចសារពើពន្ធនិងមិនមែនសារពើពន្ធ និង/ឬប្រាក់ផាកពិន័យដែលសម្បទានិកដែលមានអាជ្ញាបណ្ណត្រូវបង់ចូលថវិកាជាតិ និង/ឬមូលនិធិនានា និង/ឬការដាក់ប្រាក់តម្កល់ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគយ អនុក្រឹត្យនេះ កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ប្រកាសអន្តរក្រសួង ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

ផលិតកម្មរ៉ែ សំដៅដល់សកម្មភាពប្រតិបត្តិការជាប្រចាំដើម្បីទទួលបានផលិតផលរ៉ែក្នុងគោលបំណងពាណិជ្ជកម្មដូចជាការកិនបំបែក ប្រព្រឹត្តិកម្មញែកល្បាយរ៉ែ ប្រព្រឹត្តិកម្មរំលាយនិងបន្សុទ្ធរ៉ែ សកម្មភាពដឹកជញ្ជូនក្នុងស្រុក លោហុស្សាហកម្ម កែច្នៃរ៉ែ និងប្រតិបត្តិការផ្សេងៗទៀតមុនពេលផលិតផលរ៉ែអាចលក់បាន។

សម្បទានិកដែលមានអាជ្ញាបណ្ណ សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណស្វែងរុករកនិង/ឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ សំដៅដល់កិច្ចព្រមព្រៀងរវាងក្រសួងរ៉ែនិងថាមពលជាមួយនឹងអ្នកស្នើសុំអាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដែលត្រូវរៀបចំបំពេញបន្ថែមទៅលើអាជ្ញាបណ្ណ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលកំណត់ថា ពាក្យសុំអាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ជាគម្រោងមានទ្រង់ទ្រាយធំនិងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ។

របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព សំដៅដល់របាយការណ៍សិក្សាវាយតម្លៃគម្រោងដើម្បីកំណត់អំពីលក្ខណៈបច្ចេកទេសនិងហិរញ្ញវត្ថុ ការរៀបចំនិងការអភិវឌ្ឍធនធានរ៉ែ ផលិតកម្មរ៉ែ ការប៉ាន់ស្មានតម្លៃដើម្បីអនុវត្តគម្រោង ការវិភាគផលចំណេញនិងខាតនៃគម្រោង និងការអនុវត្តគម្រោង។

## ជំពូកទី២
## ការប្រើប្រាស់ដីក្នុងគោលបំណងស្វែងរុករក
## និងធ្វើអាជីវកម្មធនធានរ៉ែ
### ផ្នែកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៥ .-**

ដីរបស់រដ្ឋទាំងអស់អាចជាកម្មវត្ថុនៃការផ្តល់អាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

រូបវន្តបុគ្គលឬនីតិបុគ្គល អាចចេញចូលនិងធ្វើការអង្កេតសិក្សា កំណត់ទីតាំងនៅលើដីរបស់រដ្ឋទាំងនោះដើម្បីដាក់ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកស្របតាមអនុក្រឹត្យនេះ។

## ផ្នែកទី២
## តំបន់ហាមឃាត់ប្រតិបត្តិការធនធានរ៉ែ

**មាត្រា៦ ._**

ក្នុងដែននៃអាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែស្របតាមមាត្រា៥ ខាងលើ ការធ្វើបុរេសនា ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានរ៉ែ ត្រូវហាមឃាត់ចំពោះតំបន់មួយចំនួនដូចខាងក្រោមៈ

ក- តំបន់ដែលបានកំណត់ជាតំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្ត្រ តំបន់បេតិកភណ្ឌ និងតំបន់សម្រាប់កងទ័ព។

ខ- នៅក្នុងរង្វង់ចម្ងាយ១ ០០០(មួយពាន់)ម៉ែត្រជុំវិញតំបន់ក្នុងចំណុច ក ខាងលើ។

គ- តំបន់ដែលមានសំណង់អគារឬលំនៅឋានរឹងមាំ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធធំៗរួចហើយ លើកលែងតែសកម្មភាពបុរេសនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីជ្រៅមិនប៉ះពាល់ដល់លក្ខណៈវិស្វកម្មនិងបង្កហានិភ័យដល់បណ្តាហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

ឃ- នៅក្នុងរង្វង់ចម្ងាយ១០០(មួយរយ)ម៉ែត្រជុំវិញតំបន់ក្នុងចំណុច គ ខាងលើ លើកលែងតែសកម្មភាពបុរេសនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីជ្រៅមិនប៉ះពាល់ដល់លក្ខណៈវិស្វកម្មនិងបង្កហានិភ័យដល់បណ្តាហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

ង- តំបន់បញ្ចុះសព តម្កល់ទុកសព ឬទីតាំងសក្ការបូជាជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ដីសហគមន៍ជនជាតិដើមភាគតិច តំបន់បម្រុងទុក ឬតំបន់ហាមឃាត់ លើកលែងតែមានការអនុញ្ញាតដោយឡែកជាលាយលក្ខណ៍អក្សរដោយអ្នកគ្រប់គ្រងស្របច្បាប់នៃតំបន់ទាំងនោះឬអាជ្ញាធរកាន់កាប់ដីរដ្ឋ ឬសកម្មភាពបុរេសនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីលើសពី៣០(សាមសិប)ម៉ែត្រក្រោមតំបន់ទាំងនោះ។

ច- នៅក្នុងរង្វង់ចម្ងាយ១០០(មួយរយ)ម៉ែត្រជុំវិញតំបន់ក្នុងចំណុច ង ខាងលើ លើកលែងតែមានការអនុញ្ញាតដោយឡែកជាលាយលក្ខណ៍អក្សរដោយអ្នកគ្រប់គ្រងស្របច្បាប់នៃតំបន់ទាំងនោះឬអាជ្ញាធរកាន់កាប់ដីរដ្ឋ ឬសកម្មភាពបុរេសនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីលើសពី៣០(សាមសិប)ម៉ែត្រក្រោមតំបន់ទាំងនោះ។

ឆ- ដីដំណាំ សួន ស្រែ ឬចម្ការដែលមានសកម្មភាពដាំដុះ បង្កបង្កើនផលជាប់ជាប្រចាំលើកលែងតែមានការអនុញ្ញាតដោយឡែកជាលាយលក្ខណ៍អក្សរដោយអ្នកគ្រប់គ្រងស្របច្បាប់នៃតំបន់ទាំងនោះ ឬអាជ្ញាធរកាន់កាប់ដីរដ្ឋ ឬមានការសម្រេចដោយឡែកស្របតាមច្បាប់ជាធរមាន ឬសកម្មភាពបុរេសនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីលើសពី៣០(សាមសិប)ម៉ែត្រក្រោមតំបន់ទាំងនោះ។

ជ- នៅក្នុងរង្វង់ចម្ងាយ១០០(មួយរយ)ម៉ែត្រជុំវិញតំបន់ក្នុងចំណុច ឆ ខាងលើ លើកលែងតែមានការអនុញ្ញាតដោយឡែកជាលាយលក្ខណ៍អក្សរដោយអ្នកគ្រប់គ្រងស្របច្បាប់នៃតំបន់ទាំងនោះ ឬអាជ្ញាធរកាន់កាប់ដីរដ្ឋ ឬមានការសម្រេចដោយឡែកស្របតាមច្បាប់ជាធរមាន ឬសកម្មភាពបុរេសនា ស្វែងរុករក

ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីលើសពី៣០(សាមសិប)ម៉ែត្រក្រោមតំបន់ទាំងនោះ។

ឈ-នៅក្នុងរង្វង់ចម្ងាយ៥០០(ប្រាំរយ)ម៉ែត្រជុំវិញផ្លូវទឹក ទំនប់ទឹក ស្រះទឹក ឬសំណង់ប្រភពទឹកក្នុងតំបន់សម្បទានសេដ្ឋកិច្ចឬសម្បទានសង្គមកិច្ច លើកលែងតែមានការអនុញ្ញាតដោយឡែកជាលាយលក្ខណ៍អក្សរដោយអ្នកគ្រប់គ្រងស្របច្បាប់នៃតំបន់ទាំងនោះ ឬអាជ្ញាធរកាន់កាប់ដីរដ្ឋ ឬមានការសម្រេចដោយឡែកស្របតាមច្បាប់ជាធរមាន ឬសកម្មភាពបុរេសនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ប្រព្រឹត្តទៅតែនៅក្នុងលក្ខខណ្ឌជម្រៅដីមិនប៉ះពាល់ដល់លក្ខណៈវិស្វកម្មនិងបង្កហានិភ័យដល់បណ្តាហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

**មាត្រា៧ .-**

ក្នុងករណីប្រតិបត្តិការធនធានរ៉ែប្រព្រឹត្តទៅនៅក្នុងលក្ខខណ្ឌជម្រៅដីក្រោមតំបន់ដូចមានចែងក្នុងចំណុច គ ឃ ង ច ឆ ជ ឈ នៃមាត្រា៦ខាងលើ សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកកាន់កាប់ស្របច្បាប់ឬអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងរយៈពេលយ៉ាងតិច៣០(សាមសិប)ថ្ងៃមុនចាប់ផ្តើមធ្វើសកម្មភាពស្វែងរុករកឬអាជីវកម្មធនធានរ៉ែ។

**មាត្រា៨ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណអាចអនុញ្ញាតឱ្យឆ្លងកាត់តំបន់ដូចមានចែងក្នុងចំណុច ខ ឃ ច ជ ឈ នៃមាត្រា៦ខាងលើ ទៅកាន់តំបន់ផ្សេងទៀតដើម្បីធ្វើការស្វែងរុករកឬអាជីវកម្មធនធានរ៉ែ។

ក្នុងការឆ្លងកាត់តំបន់ដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវទទួលខុសត្រូវសងការខូចខាតនានាស្របតាមមាត្រា២៥នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៩ .-**

ក្នុងការឆ្លងកាត់តំបន់ដែលបានកំណត់ក្នុងមាត្រា៨ខាងលើ សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវ៖

- ជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់អ្នកគ្រប់គ្រងស្របច្បាប់ឬអាជ្ញាធរកាន់កាប់ដីរដ្ឋនៃតំបន់ខាងលើក្នុងរយៈពេលយ៉ាងតិច៧(ប្រាំពីរ)ថ្ងៃមុននឹងធ្វើការឆ្លងកាត់
- ចាត់វិធានការសមស្របនិងគ្រប់គ្រាន់ ដើម្បីបង្ការការពារអគ្គិភ័យ ការខូចខាតដំណាំ ដើមឈើ សត្វចិញ្ចឹម ឬទ្រព្យសម្បត្តិផ្សេងៗ ដោយប្រឹងប្រែងអស់លទ្ធភាពក្នុងការធ្វើឱ្យការបង្កការរំខានមានកម្រិតតិចតួចបំផុតតាមដែលអាចធ្វើទៅបាន
- ស្តារឡើងវិញឬកែលម្អឡើងវិញ ឱ្យបានសមស្របចំពោះការខូចខាតនានា។

## ផ្នែកទី៣
## ប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ការពារធម្មជាតិនិងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍

### មាត្រា១០ .-

អាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ អាចផ្តល់នៅក្នុងតំបន់ការពារធម្មជាតិនិងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់គ្រប់គ្រងតំបន់ទាំងនោះនិងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

ការផ្តល់អាជ្ញាបណ្ណស្វែងរុករកនិងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នៅក្នុងតំបន់ការពារធម្មជាតិនិងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការឯកភាពពីក្រសួងឬស្ថាប័នគ្រប់គ្រងតំបន់ទាំងនោះ។

ការធ្វើបុរេសនា ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានរ៉ែ នៅក្នុងតំបន់ការពារធម្មជាតិនិងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាននិងធម្មជាតិ។

### មាត្រា១១ .-

ក្នុងករណីមានតម្រូវការឆ្លងកាត់តំបន់ការពារធម្មជាតិឬតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដើម្បីធ្វើបុរេសនា ស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែនៅតំបន់ផ្សេងទៀត សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និង/ឬរដ្ឋបាលព្រៃឈើប្រចាំតំបន់ការពារធម្មជាតិឬតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ។ សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវ៖

- ចាត់វិធានការសមស្របនិងគ្រប់គ្រាន់ដើម្បីបង្ការការពារអគ្គិភ័យ ការប៉ះពាល់ខូចខាតដី ដើមឈើ ឬធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ
- សុំការអនុញ្ញាតជាមុនចំពោះរាល់ការបង្កឱ្យមានការខូចខាតដី ដើមឈើ ឬធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ និង
- ស្តារឡើងវិញឬកែលម្អឡើងវិញឱ្យបានសមស្របចំពោះការខូចខាតនានាដែលបានបង្កឡើង។

## ផ្នែកទី៤
## ការកាត់តំបន់សម្រាប់អភិវឌ្ឍទីក្រុងពីតំបន់ប្រតិបត្តិការធនធានរ៉ែ

### មាត្រា១២ .-

ក្នុងករណីតំបន់ទាំងមូលឬផ្នែកណាមួយ នៃដែនអាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ស្ថិតក្នុងប្រភេទដីធ្លីសម្រាប់ការអភិវឌ្ឍក្រុងស្របតាមច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ អាចស្នើសុំឱ្យមានការកាត់ចេញនូវតំបន់ឬផ្នែកនោះ ដោយផ្អែកលើតម្រូវការផលប្រយោជន៍សាធារណៈដើម្បីបម្រើដល់ការអភិវឌ្ឍទីក្រុង លើកលែងតែតំបន់នោះគឺជាតំបន់ដែលកំណត់ដោយបញ្ញត្តិច្បាប់រួចហើយថាជាតំបន់ការពារធនធានរ៉ែ។

ក្នុងករណីដែលមានការស្នើសុំដោយគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សម្បទានិកដែលមានអាជ្ញាបណ្ណ អំពីការតម្រូវឱ្យធ្វើការកាត់ចេញពីដែនអាជ្ញាបណ្ណ។ ក្នុងរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃយ៉ាងយូរ បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតជូនដំណឹង សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវរៀបចំនិងជូនដំណឹង ដល់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអំពីនីតិវិធី កម្មវិធីការងារ និងលក្ខខណ្ឌបច្ចេកទេសតម្រូវចាំបាច់នានា សម្រាប់បិទបញ្ចប់សកម្មភាពស្វែងរុករករ៉ែឬសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មធនធានរ៉ែ និងការស្តារឡើងវិញ នៅក្នុងតំបន់ដែលត្រូវកាត់ចេញនិងត្រូវប្រគល់ផ្ទៃក្រឡាសងវិញស្របតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណបានបង្ហាញឱ្យឃើញពីសក្តានុពលធនធានរ៉ែឬតម្រូវការ ដើម្បីបញ្ចប់ការស្វែងរុករកនៅក្នុងតំបន់ដែលត្រូវកាត់ចេញ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល អាចធ្វើការសម្របសម្រួលដើម្បីពន្យារការកាត់តំបន់ដើម្បី អភិវឌ្ឍទីក្រុងចេញពីដែនអាជ្ញាបណ្ណ។

**មាត្រា១៣ .-**

ផុតរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃដូចមានកំណត់ក្នុងមាត្រា១២ខាងលើ ប្រសិនបើសម្បទានិក ដែលមានអាជ្ញាបណ្ណមិនបានឆ្លើយតបនឹងការជូនដំណឹងរបស់ក្រសួងរ៉ែនិងថាមពល តំបន់នោះត្រូវកាត់ចេញ ដោយស្វ័យប្រវត្តិ ហើយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវកែតម្រូវលក្ខខណ្ឌនិងកាតព្វកិច្ចនានានិងទំហំផ្ទៃដី នៃដែនអាជ្ញាបណ្ណឡើងវិញ ស្របតាមនីតិវិធីនៃការកាត់ចេញដែលត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រី ក្រសួងរ៉ែនិងថាមពល។

ប្រសិនបើការអភិវឌ្ឍក្រុងត្រូវបានខកខានមិនអនុវត្ត ឬលែងមានតម្រូវការវិញ ឬមានសេចក្តីសម្រេច ផ្សេងដោយរាជរដ្ឋាភិបាល សម្បទានិកដែលមានអាជ្ញាបណ្ណដែលត្រូវបានកាត់ចេញអាចស្នើសុំតំបន់ដែល បានកាត់ចេញនោះឡើងវិញដើម្បីបន្តប្រតិបត្តិការធនធានរ៉ែ។

**មាត្រា១៤ .-**

ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណបានវិនិយោគសាងសង់ហេដ្ឋារចនាសម្ព័ន្ធរឹងមាំឬបាន អភិវឌ្ឍរចនាសម្ព័ន្ធពាក់ព័ន្ធនឹងអាជីវកម្មធនធានរ៉ែរួចហើយ មុនពេលតំបន់ត្រូវបានកាត់ចេញស្របតាម មាត្រា១២ខាងលើ សម្បទានិកមានសិទ្ធិទាមទារនិងទទួលបានសំណងចំពោះការខូចខាតលើសំណង់ អគារឬហេដ្ឋារចនាសម្ព័ន្ធទាំងនោះស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

## ផ្នែកទី៥
## ប្រតិបត្តិការធនធានរ៉ែក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចនិងព្រៃសម្បទាន

**មាត្រា១៥ .-**

តំបន់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន អាចជាកម្មវត្ថុនៃការផ្តល់អាជ្ញាបណ្ណស្វែងរុករកឬ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

មុនការផ្តល់អាជ្ញាបណ្ណស្វែងរុករកលើតំបន់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវសហការជាមួយនឹងរដ្ឋមន្ត្រីទទួលបន្ទុកគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ដើម្បីសិក្សាវាយតម្លៃផលប៉ះពាល់របស់ប្រតិបត្តិការធនធានរ៉ែ ចំពោះសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាននិងលើកសំណើសុំការសម្រេចពីរាជរដ្ឋាភិបាល។

អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែអាចផ្តល់ជូនសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកនៅលើតំបន់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ដោយផ្អែកលើគោលការណ៍ប្រៀបធៀបផលប្រយោជន៍សេដ្ឋកិច្ចសង្គមរយៈពេលវែងរវាងគម្រោងសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ជាមួយនឹងគម្រោងអាជីវកម្មធនធានរ៉ែ។ ក្នុងករណីអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានសម្រេចផ្តល់ជូនសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវជូនដំណឹងដល់ក្រសួងស្ថាប័នពាក់ព័ន្ធនិងម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទានអំពីការតម្រូវឱ្យកាត់ផ្ទៃដីនៃដែនអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែចេញពីតំបន់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ហើយក្រសួងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តនីតិវិធីចាំបាច់នានា ដើម្បីកែសម្រួលផ្ទៃដីតំបន់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទានស្របតាមការកាត់ចេញនេះ។

**មាត្រា១៦ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវខិតខំអស់ពីលទ្ធភាពក្នុងការបញ្ចៀសរាល់ការរំខានឬផលប៉ះពាល់នានា បង្កឡើងដោយប្រតិបត្តិការធនធានរ៉ែ និងត្រូវទូទាត់សំណងលើរាល់ផលប៉ះពាល់និងខូចខាតលើសំណង់ ហេដ្ឋារចនាសម្ព័ន្ធរឹងមាំដែលបានសាងសង់រួច ឬដើមឈើ ឬដំណាំដាំដុះ ដោយការវិនិយោគរបស់ម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទានស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែនិងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

**មាត្រា១៧ .-**

ក្នុងករណីដែលផ្ទៃដីទាំងមូលឬចំណែកណាមួយ នៃតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅក្នុងអាជ្ញាបណ្ណស្វែងរុករកនិង/ឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ មិនទាន់បានផ្តល់ជាសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទានជូនទៅបុគ្គលណាម្នាក់ទេនោះ ស្ថាប័នទទួលបន្ទុកគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន មិនអាចផ្តល់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន លើផ្ទៃដីទាំងមូលឬចំណែកណាមួយនៃតំបន់ប្រតិបត្តិការធនធានរ៉ែដែលមានកំណត់នៅក្នុងអាជ្ញាបណ្ណស្វែងរុករកនិង/ឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែទៅឱ្យបុគ្គលណាម្នាក់បានឡើយ លើកលែងតែមានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមសំណើរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា១៨ .-**

ម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ត្រូវទទួលខុសត្រូវទូទាត់សំណងដល់សម្បទានិកដែលមានអាជ្ញាបណ្ណ ចំពោះផលប៉ះពាល់ ការបង្កការរំខានដល់ប្រតិបត្តិការធនធានរ៉ែ ឬការខូចខាតដល់

ទ្រព្យសម្បត្តិការដ្ឋានរ៉ែឬសំណាកគំរូរ៉ែ ដែលបង្កដោយសកម្មភាពសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន។ ក្នុងករណីពុំមានការឯកភាពលើតម្លៃនៃសំណង រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវធ្វើការសម្របសម្រួលអំពីសំណងផ្អែកតាមការពិនិត្យនិងសិក្សាវាយតម្លៃរបស់ជំនាញការឯករាជ្យមួយដែលត្រូវបានជ្រើសរើសតាមការព្រមព្រៀងរបស់សម្បទានិកដែលមានអាជ្ញាបណ្ណនិងម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន។ សោហ៊ុយចំណាយលើជំនាញការឯករាជ្យនេះជាបន្ទុកម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន។

**មាត្រា១៩ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន អំពីផែនការប្រតិបត្តិការធនធានរ៉ែសំខាន់ៗដែលអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន អំពីតំបន់អភិវឌ្ឍធនធានរ៉ែ ការដ្ឋានអាជីវកម្មធនធានរ៉ែ អណ្តូងរ៉ែ ទីតាំងស្តុកទីបម្រុងដីករ៉ែ ទីសម្រាប់ប្រើប្រាស់ទូទៅក្នុងសកម្មភាពអាជីវកម្មធនធានរ៉ែ គម្រោងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាពាក់ព័ន្ធនឹងតំបន់ការពារធនធានរ៉ែដែលតម្រូវកាត់ចេញវិញពីតំបន់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទានឱ្យបានឆាប់តាមដែលអាចធ្វើបានដើម្បីសម្រួលដល់ការរៀបចំផែនការអភិវឌ្ឍរបស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន។

**មាត្រា២០ .-**

ម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ត្រូវបង្កលក្ខណៈងាយស្រួលដល់សម្បទានិកដែលមានអាជ្ញាបណ្ណក្នុងសកម្មភាពប្រតិបត្តិការធនធានរ៉ែក្នុងតំបន់សម្បទានរបស់ខ្លួននិងខិតខំឱ្យអស់លទ្ធភាពក្នុងការសម្របសម្រួលបញ្ចៀសទំនាស់ប្រើប្រាស់ដីធ្លីរវាងភាគីពាក់ព័ន្ធ។

ក្នុងករណីកថាខណ្ឌទី១ខាងលើពុំអាចអនុវត្តបាន រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចកំណត់លក្ខខណ្ឌតម្រូវឱ្យមានកិច្ចសម្របសម្រួលនិងកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធលើការប្រើប្រាស់ដីធ្លីនិងដោះស្រាយទំនាស់ក្នុងការប្រើប្រាស់ដីក្រោយពីមានការពិគ្រោះយោបល់ជាមួយនឹងអាជ្ញាធរមូលដ្ឋាននិងសមត្ថកិច្ចពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន។

ក្នុងករណីម្ចាស់សម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន ខកខានមិនបានអនុវត្តតាមកថាខណ្ឌទី២ខាងលើដោយគ្មានមូលហេតុសមស្រប សកម្មភាពសម្បទានដីសេដ្ឋកិច្ចឬព្រៃសម្បទាន នៅក្នុងតំបន់មានទំនាស់ត្រូវផ្អាកជាបណ្តោះអាសន្នដើម្បីអនុញ្ញាតឱ្យសកម្មភាពប្រតិបត្តិការធនធានរ៉ែអាចប្រព្រឹត្តទៅបាន។

## ផ្នែកទី៦
## ប្រតិបត្តិការធនធានរ៉ែលើដីឯកជន

**មាត្រា២១ .-**

អាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ អាចផ្តល់លើដីឯកជនដោយត្រូវអនុលោមតាមច្បាប់ភូមិបាលនិងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាននិងត្រូវមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនរវាងអ្នកស្នើសុំអាជ្ញាបណ្ណជាមួយនឹងកម្មសិទ្ធិករនិង/ឬអ្នកកាន់កាប់ប្រើប្រាស់ដីស្របច្បាប់។

ដោយឡែកចំពោះគម្រោងសកម្មភាពសិក្សាស្វែងរុករកនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលអនុវត្តក្នុងលក្ខខណ្ឌជម្រៅដីជ្រៅដែលមិនបង្កផលប៉ះពាល់ដល់លក្ខណៈវិស្វកម្មនិងបង្កហានិភ័យ ដល់បណ្តាហេដ្ឋារចនាសម្ព័ន្ធណាមួយនៅលើផ្ទៃដី ការផ្តល់អាជ្ញាបណ្ណស្វែងរុករកនិង/ឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមិនតម្រូវឱ្យមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងអ្នកស្នើសុំអាជ្ញាបណ្ណជាមួយនឹងកម្មសិទ្ធិករឬអ្នកកាន់កាប់ប្រើប្រាស់ដីស្របច្បាប់ទេ។

អ្នកស្នើសុំអាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ស្របតាមកថាខណ្ឌទី២ខាងលើត្រូវជូនដំណឹងអំពីពាក្យស្នើសុំរបស់ខ្លួនដល់កម្មសិទ្ធិករឬអ្នកកាន់កាប់ប្រើប្រាស់ដីស្របច្បាប់ដែលពាក់ព័ន្ធនិងដល់អាជ្ញាធរមូលដ្ឋានដែលទីតាំងដីឯកជននោះស្ថិតនៅ។ កម្មសិទ្ធិករនិង/ឬអ្នកកាន់កាប់ប្រើប្រាស់ដីស្របច្បាប់ អាចប្តឹងតវ៉ាចំពោះការផ្តល់អាជ្ញាបណ្ណនេះដោយអនុលោមតាមមាត្រា២៧នៃអនុក្រឹត្យនេះ។

**មាត្រា២២.-**

មុននឹងធ្វើការឆ្លងកាត់ដីឯកជន សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីកម្មសិទ្ធិករ ឬអ្នកដែលទទួលសិទ្ធិស្របច្បាប់ ឬអ្នកកាន់កាប់ប្រើប្រាស់ដីស្របច្បាប់ ហើយត្រូវសងទៅកម្មសិទ្ធិករឬអ្នកកាន់កាប់ប្រើប្រាស់ដីស្របច្បាប់ ទាំងក្នុងនិងក្រៅតំបន់អាជ្ញាបណ្ណចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន ដោយមិនគិតថាការខូចខាតនោះជាឧបទ្ទវហេតុឬជាការដឹងជាមុនឡើយ។

## ជំពូកទី៣
## អាជ្ញាបណ្ណស្វែងរុករក

**មាត្រា២៣.-**

ប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណស្វែងរុករករួមមាន បុរេសនា ការស្វែងរុករក និងការវាយតម្លៃសេដ្ឋកិច្ចនៃជម្រករ៉ែ។

ការវាយតម្លៃសេដ្ឋកិច្ចជម្រករ៉ែរួមមាន ការវាយតម្លៃទំហំជម្រករ៉ែ ការសិក្សាសមិទ្ធិលទ្ធភាព ការសិក្សានិងសាកល្បងបច្ចេកទេសជីកយក បច្ចេកទេសប្រព្រឹត្តកម្មចម្រាញ់យករ៉ែ ការអង្កេតវាយតម្លៃផ្លូវដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធផ្សេងៗ និងការសិក្សាទីផ្សារនិងហិរញ្ញប្បទាន។

**មាត្រា២៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គល អាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើការសិក្សាវាយតម្លៃបឋមមុននឹងស្នើសុំអាជ្ញាបណ្ណស្វែងរុករក។ ក្នុងករណីដែលរូបវន្តបុគ្គលឬនីតិបុគ្គលនោះមានរបាយការណ៍ ព័ត៌មាន និងទិន្នន័យគ្រប់គ្រាន់ពីសក្តានុពលនៃធនធានរ៉ែ រូបវន្តបុគ្គលឬនីតិបុគ្គល អាចធ្វើការស្នើសុំអាជ្ញាបណ្ណស្វែងរុករក។ ការសិក្សាវាយតម្លៃបឋមមានគោលដៅប្រមូលទិន្នន័យឬព័ត៌មាន ទាក់ទងនឹងភូគព្ភសាស្ត្រ ស្ថានភាពកម្មសិទ្ធិនិងការប្រើប្រាស់ដី ផលប៉ះពាល់ដែលនឹងអាចកើតឡើងចំពោះសកម្មភាពសេដ្ឋកិច្ច បរិស្ថាន និងសហគមន៍មូលដ្ឋាន។

ការសិក្សាវាយតម្លៃបឋមមិនត្រូវធ្វើក្នុងតំបន់ដែលបានផ្តល់អាជ្ញាបណ្ណស្វែងរុករកនិង/ឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដែលមានរួចហើយនោះទេ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចចេញលិខិតអនុញ្ញាតឱ្យរូបវន្តបុគ្គលឬនីតិបុគ្គល ដើម្បីធ្វើការសិក្សាវាយតម្លៃបឋមនេះតាមនីតិវិធីនិងលក្ខខណ្ឌកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។ រូបវន្តបុគ្គលឬនីតិបុគ្គល ដែលទទួលបានលិខិតអនុញ្ញាតនេះពុំត្រូវបានផ្តល់សិទ្ធិផ្តាច់មុខក្នុងការសិក្សាវាយតម្លៃបឋមឬអាទិភាព ក្នុងការផ្តល់អាជ្ញាបណ្ណស្វែងរុករកទេ។

លិខិតអនុញ្ញាតផ្តល់ជូនស្របតាមមាត្រានេះមានសុពលភាពមិនលើសពី៦(ប្រាំមួយ)ខែបន្ទាប់ពីកាលបរិច្ឆេទចេញលិខិត ហើយអាចពន្យារបានតែម្តងគត់សម្រាប់រយៈពេល៣(បី)ខែ។ ផុតរយៈពេលដូចបានកំណត់នេះ រូបវន្តបុគ្គលឬនីតិបុគ្គលនោះមិនអាចស្នើសុំលិខិតអនុញ្ញាតលើកទីពីរសម្រាប់តំបន់ដដែលទេ ប៉ុន្តែអាចស្នើសុំលិខិតអនុញ្ញាតសម្រាប់ការវាយតម្លៃបឋមសម្រាប់តំបន់ផ្សេងទៀតបាន។

**មាត្រា២៥ .-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើការសិក្សាវាយតម្លៃបឋមស្របតាមមាត្រា២៤ខាងលើអាចដឹកយកសំណាករ៉ែក្នុងរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតសរុបទាំងអស់យ៉ាងច្រើន២៥(ម្ភៃប្រាំ)តោន។ បរិមាណសំណាករ៉ែលើសពីនេះត្រូវស្នើសុំការអនុញ្ញាតបន្ថែមពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលទទួលបានលិខិតអនុញ្ញាតឱ្យធ្វើការសិក្សាវាយតម្លៃបឋមត្រូវអនុវត្តប្រតិបត្តិការតែនៅស្រទាប់ដីលើដោយប្រើប្រាស់ឧបករណ៍សាមញ្ញនិងកាត់បន្ថយការប៉ះពាល់ដល់ផ្ទៃដី។

**មាត្រា២៦ .-**

ដើម្បីទទួលបានអាជ្ញាបណ្ណស្វែងរុករក រូបវន្តបុគ្គលឬនីតិបុគ្គល ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកទៅក្រសួងរ៉ែនិងថាមពល។

ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកត្រូវបំពេញតាមទម្រង់និងបែបបទ ដោយមានភ្ជាប់នូវឯកសារព័ត៌មានចាំបាច់ដូចខាងក្រោម៖

- សំណើអំពីវិធីសាស្ត្រ កម្មវិធីការងារស្វែងរុករកលម្អិត គម្រោងប៉ាន់ស្មានថវិកា ធនធានជំនាញបច្ចេកទេស និងប្រភពហិរញ្ញប្បទានដែលមាន ដើម្បីអនុវត្តតាមកម្មវិធីដែលស្នើឡើង
- លក្ខន្តិកៈក្រុមហ៊ុននិងលិខិតចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សក្ខីបត្របញ្ជាក់អំពីការបង់កម្រៃទទួលពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករក
- របាយការណ៍សិក្សាវាយតម្លៃបឋមឬរបាយការណ៍ព័ត៌មាន និងទិន្នន័យដូចចែងក្នុងមាត្រា២៤នៃអនុក្រឹត្យនេះ
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង និង
- ឯកសារនិងព័ត៌មានចាំបាច់ផ្សេងៗទៀតតាមការចាំបាច់ និងតាមស្ថានភាពជាក់ស្តែងនីមួយៗតាមការកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ទម្រង់និងបែបបទលម្អិត នៃពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

វិញ្ញាបនបត្រចុះបញ្ជីពន្ធដារនិងបណ្ណពន្ធប៉ាតង់ឆ្នាំចរន្ត ត្រូវផ្តល់ជូនក្រសួងរ៉ែនិងថាមពលក្រោយទទួលបានអាជ្ញាបណ្ណស្វែងរុករក។

រាល់ការទទួលពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកត្រូវមានការចុះបញ្ជីនិងកំណត់ត្រាកាលបរិច្ឆេទទទួលពាក្យ ហើយត្រូវប្រកាសផ្សាយក្នុងគេហទំព័រក្រសួងរ៉ែនិងថាមពល។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលបានបំពេញតាមលក្ខខណ្ឌចាំបាច់ខាងលើមុនគេ មានអាទិភាពក្នុងការទទួលបានការផ្តល់អាជ្ញាបណ្ណស្វែងរុករកលើតំបន់ដែលស្នើសុំ។

ក្នុងករណីមានរូបវន្តបុគ្គលឬនីតិបុគ្គលពីរឬច្រើនបានបំពេញតាមលក្ខខណ្ឌចាំបាច់ខាងលើនិងបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណស្វែងរុករកក្នុងពេលដំណាលគ្នា រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវកំណត់សិទ្ធិទទួលបានអាទិភាពក្នុងការទទួលបានការផ្តល់អាជ្ញាបណ្ណស្វែងរុករក ដោយត្រូវធ្វើការចាប់ឆ្នោតជាសាធារណៈ លើកលែងតែមានការឯកភាពពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការផ្តល់អាទិភាពដោយមិនចាំបាច់ធ្វើការចាប់ឆ្នោត។

**មាត្រា២៧.-**

អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលទីតាំងស្នើសុំស្ថិតនៅត្រូវផ្សព្វផ្សាយជាបន្ទាន់ ជាសាធារណៈនូវសេចក្តីជូនដំណឹងរបស់ក្រសួងរ៉ែនិងថាមពលស្តីពីការស្នើសុំអាជ្ញាបណ្ណស្វែងរុករកនេះ។

បុគ្គលពាក់ព័ន្ធដែលមានបំណងតវ៉ាលើការផ្តល់អាជ្ញាបណ្ណស្វែងរុករកអាចដាក់ពាក្យស្នើសុំតវ៉ាទៅមន្ទីររ៉ែនិងថាមពលនៅតាមរាជធានី ខេត្តឬក្រសួងរ៉ែនិងថាមពល តាមរយៈឃុំ សង្កាត់ពាក់ព័ន្ធក្នុងរយៈពេល ៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរបន្ទាប់ពីការបិទផ្សាយសេចក្តីជូនដំណឹងរបស់ក្រសួងរ៉ែនិងថាមពលនៅតាមឃុំ សង្កាត់ពាក់ព័ន្ធ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវពិនិត្យនិងដោះស្រាយ ពាក្យស្នើសុំតវ៉ាក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យស្នើសុំតវ៉ា។

បែបបទ នីតិវិធីនៃការទទួល និងការដោះស្រាយពាក្យស្នើសុំតវ៉ាត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា២៨.-**

បន្ទាប់ពីបានពិនិត្យលទ្ធផលនៃការសិក្សាវាយតម្លៃបឋម ឬរបាយការណ៍ព័ត៌មាន និងទិន្នន័យគ្រប់គ្រាន់ និងបន្ទាប់ពីបានដោះស្រាយពាក្យស្នើសុំតវ៉ារួចរាល់ហើយ ក្នុងករណីមានពាក្យស្នើសុំតវ៉ា រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចផ្តល់អាជ្ញាបណ្ណស្វែងរុករកតាមសំណើរបស់រូបវន្តបុគ្គលឬនីតិបុគ្គលទៅតាមការពិនិត្យពិច័យលើសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៩.-**

តំបន់អាជ្ញាបណ្ណស្វែងរុករកដែលអាចផ្តល់ជូនត្រូវផ្គុំឡើងជាតំបន់តែមួយដោយប្លុកចតុកោណឬពហុកោណ និងមានទំហំផ្ទៃដីមិនលើសពី២០០(ពីររយ)គីឡូម៉ែត្រការ៉េ។ ក្នុងករណីចាំបាច់ដែលមាន

សំណើសុំតំបន់អាជ្ញាបណ្ណស្វែងរុករកលើសពី២០០(ពីររយ)គីឡូម៉ែត្រការ៉េ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ត្រូវស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល។

រូបវន្តបុគ្គលឬនីតិបុគ្គល អាចទទួលបានអាជ្ញាបណ្ណស្វែងរុករកលើសពីមួយស្របតាមលក្ខខណ្ឌ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៣០ .-**

ចំពោះតំបន់ដែលមិនទាន់ចេញអាជ្ញាបណ្ណធនធានរ៉ែ ហើយបានដឹងពីសក្តានុពលធនធានរ៉ែតាមរយៈ ការខួងអណ្តូងសិក្សាជាមួយសំណាករ៉ែលើសពី១០(ដប់)ទីតាំងរួចហើយនិង/ឬតំបន់ដែលធ្លាប់មានសកម្មភាព អាជីវកម្មធនធានរ៉ែ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវកំណត់ដោយប្រកាសជាសាធារណៈថាជាតំបន់រក្សា ទុកសម្រាប់ធ្វើការដេញថ្លៃ ដើម្បីទទួលបានអាជ្ញាបណ្ណស្វែងរុករកស្របតាមមាត្រា១៣នៃច្បាប់ស្តីពីការ គ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ។

**មាត្រា៣១ .-**

ក្នុងគោលបំណងការពារផលប្រយោជន៍សាធារណៈនិងសង្គម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាច បដិសេធសំណើសុំអាជ្ញាបណ្ណស្វែងរុករកលើតំបន់ស្នើសុំទាំងមូលឬបដិសេធលើចំណែកណាមួយនៃតំបន់ ស្នើសុំតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំ។

**មាត្រា៣២ .-**

មុនការផ្តល់អាជ្ញាបណ្ណស្វែងរុករកឬការអនុញ្ញាតពន្យារសុពលភាពបន្តអាជ្ញាបណ្ណស្វែងរុករក អ្នកដាក់ ពាក្យស្នើសុំឬសម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវដាក់ប្រាក់តម្កល់ធានាកាតព្វកិច្ចដូចមានចែងក្នុងអនុក្រឹត្យ នេះចូលក្នុងគណនីទោលរតនាគាររបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅក្នុងធនាគារជាតិនៃកម្ពុជាសម្រាប់ រយៈពេលសុពលភាពអាជ្ញាបណ្ណតាមទម្រង់និងលក្ខខណ្ឌកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ប្រាក់តម្កល់ធានាកាតព្វកិច្ចនេះនឹងត្រូវរឹបអូសជាប្រយោជន៍របស់រដ្ឋក្នុងករណីដែលអាជ្ញាបណ្ណ ស្វែងរុករកត្រូវបានដកហូតដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៣៩ឬមាត្រា៤០នៃអនុក្រឹត្យនេះ។

អាជ្ញាបណ្ណស្វែងរុករកឬការអនុញ្ញាតពន្យារសុពលភាពបន្ត មិនត្រូវបានផ្តល់ជូនទេក្នុងករណីដែល អ្នកដាក់ពាក្យស្នើសុំឬសម្បទានិកដែលមានអាជ្ញាបណ្ណ មិនបានអនុវត្តត្រឹមត្រូវស្របតាមកថាខណ្ឌទី១ ខាងលើ។

**មាត្រា៣៣ .-**

អាជ្ញាបណ្ណស្វែងរុករកមានសុពលភាពរយៈពេល៣(បី)ឆ្នាំចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាផ្តល់ អាជ្ញាបណ្ណ។

សុពលភាពនៃអាជ្ញាបណ្ណស្វែងរុករកនេះអាចពន្យារបានពីរដង ដោយម្តងៗមានរយៈពេលពីរឆ្នាំ ប្រសិនបើមានមូលហេតុណាមួយដូចខាងក្រោម៖

- សម្បទានិកដែលមានអាជ្ញាបណ្ណបានអនុវត្តស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ និងបានបញ្ចប់ការងារសំខាន់ៗស្របតាមផែនការសកម្មភាព

ហើយលទ្ធផលនៃការរុករករ៉ែបានបង្ហាញពីសក្តានុពលធនធានរ៉ែ ប៉ុន្តែតម្រូវឱ្យមានការសិក្សាវាយតម្លៃបន្ថែម

- សម្បទានិកដែលមានអាជ្ញាបណ្ណមានការលំបាកជាក់ស្តែងដែលបណ្តាលមកពីការពន្យារពេលដោយច្បាប់តម្រូវ វិធានការរដ្ឋបាល នយោបាយ ការតម្រូវដោយរាជរដ្ឋាភិបាលឬស្ថាប័នមានសមត្ថកិច្ចចំពោះកាតព្វកិច្ចការពារបរិស្ថាននិងសង្គម
- សម្បទានិកដែលមានអាជ្ញាបណ្ណមានការលំបាកឬយឺតយ៉ាវ ក្នុងការទទួលបានសិទ្ធិឆ្លងកាត់ក្នុងតំបន់អាជ្ញាបណ្ណឬដោយសារស្ថានភាពអាកាសធាតុដែលបង្កឧបសគ្គរារាំងដល់សម្បទានិកដែលមានអាជ្ញាបណ្ណមិនឱ្យអនុវត្តប្រតិបត្តិការធនធានរ៉ែបានត្រឹមត្រូវតាមកម្មវិធីការងារដែលបានឯកភាព
- មានករណីតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណធ្វើការសិក្សាអង្កេតស្ថានភាពសេដ្ឋកិច្ច សង្គម ផលប៉ះពាល់ បរិស្ថាន និងបេតិកភណ្ឌ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចផ្តល់ការពន្យារសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករកបានដើម្បីអនុញ្ញាតឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកធ្វើការបញ្ចប់របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែដែលរយៈពេលពន្យារបន្ថែមម្តងៗមិនលើសពី២(ពីរ)ឆ្នាំ។ ក្នុងករណីមានការបដិសេធការអនុញ្ញាតពន្យារបន្តសុពលភាពអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរ។

**មាត្រា៣៤ .-**

ពាក្យស្នើសុំពន្យារសុពលភាពអាជ្ញាបណ្ណស្វែងរុករកបន្តត្រូវដាក់ឱ្យបានមុនកាលបរិច្ឆេទអាជ្ញាបណ្ណអស់សុពលភាព។ ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណខកខានឬពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពអាជ្ញាបណ្ណទាន់ពេលវេលាកំណត់នោះទេ អាជ្ញាបណ្ណស្វែងរុករកនិង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែពាក់ព័ន្ធ ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ ហើយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចេញប្រកាសជូនដំណឹងអំពីការបញ្ចប់នេះ។

ក្នុងករណីអាជ្ញាបណ្ណអស់សុពលភាព ប៉ុន្តែសម្បទានិកដែលមានអាជ្ញាបណ្ណបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពអាជ្ញាបណ្ណត្រឹមត្រូវតាមពេលកំណត់ អាជ្ញាបណ្ណនោះនៅតែមានសុពលភាពបន្តរហូតដល់មានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលលើពាក្យស្នើសុំ។

ការពន្យាររយៈពេលសុពលភាពអាជ្ញាបណ្ណស្វែងរុករកបន្ថែមអាចអនុញ្ញាតសម្រាប់តំបន់ទាំងមូល ឬចំណែកណាមួយ នៃតំបន់អាជ្ញាបណ្ណស្វែងរុករកដែលនៅសល់បន្ទាប់ពីការប្រគល់ផ្ទៃក្រឡាសងវិញ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរ ក្នុងករណីបដិសេធការអនុញ្ញាតពន្យារសុពលភាពអាជ្ញាបណ្ណបន្ត។

ក្រោយពេលបានដាក់ពាក្យស្នើសុំពន្យារសុពលភាពអាជ្ញាបណ្ណបន្តរួចហើយ ប្រសិនបើសម្បទានិកដែលមានអាជ្ញាបណ្ណធ្វើការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ ពាក្យស្នើសុំពន្យារបន្តសុពលភាពនៃអាជ្ញាបណ្ណដែលបានដាក់ពីមុនត្រូវចាត់ទុកជាពាក្យស្នើសុំរបស់អ្នកដែលបានទទួលសិទ្ធិបន្ត។

**មាត្រា៣៥ .-**

ក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករក សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវបំពេញកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាក្នុងប្រតិបត្តិការធនធានរ៉ែពាក់ព័ន្ធនឹងការស្វែងរុករក លើកលែងតែ

មានការអនុញ្ញាតដោយឡែកពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលស្របតាមអនុក្រឹត្យនេះឬមានការចែងដោយឡែកនៅក្នុងអាជ្ញាបណ្ណនិង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ។

កាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាដែលកំណត់ក្នុងមាត្រានេះត្រូវគណនាតាមប្រភេទចំណាយដូចមានចែងក្នុងមាត្រា៩១នៃអនុក្រឹត្យនេះនិងតាមកម្រិតអប្បបរមាតម្រូវដូចតទៅៈ

- ចាប់ពីឆ្នាំទី១ដល់ទី៣យ៉ាងតិច១ ០០០ ០០០(មួយលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េនៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង១០០(មួយរយ)គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង១០០ ០០០ ០០០(មួយរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៤ដល់ទី៥យ៉ាងតិច៤ ០០០ ០០០(បួនលាន)រៀលក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េនៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង១០០(មួយរយ)គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង៤០០ ០០០ ០០០(បួនរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៦ដល់ទី៧យ៉ាងតិច៦ ០០០ ០០០(ប្រាំមួយលាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េនៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង១០០(មួយរយ)គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង៦០០ ០០០ ០០០(ប្រាំមួយរយលាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល
- ចាប់ពីឆ្នាំទី៨តទៅយ៉ាងតិច១០ ០០០ ០០០(ដប់លាន)រៀល ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េនៃដែនអាជ្ញាបណ្ណក្នុងមួយឆ្នាំ ហើយក្នុងករណីដែនអាជ្ញាបណ្ណតូចជាង១០០(មួយរយ)គីឡូម៉ែត្រការ៉េ នោះកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមិនត្រូវតិចជាង១ ០០០ ០០០ ០០០(មួយពាន់លាន)រៀលក្នុងមួយឆ្នាំសម្រាប់ដែនអាជ្ញាបណ្ណទាំងមូល។

ក្នុងឆ្នាំចាប់ផ្តើមដំបូងនិងឆ្នាំបញ្ចប់សុពលភាពអាជ្ញាបណ្ណ លក្ខខណ្ឌចំណាយខាងលើអាចគណនាតាមសមាមាត្រជាក់ស្តែងនៃចំនួនខែក្នុងឆ្នាំនីមួយៗ។

ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកទទួលបានការអនុញ្ញាតរក្សាទុកសុពលភាពរបស់អាជ្ញាបណ្ណស្វែងរុករកទាំងមូលឬចំណែកណាមួយ កាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាតម្រូវក្នុងមាត្រានេះត្រូវកាត់បន្ថយបរិមាណតាមចំនួនសមាមាត្រទៅនឹងបរិមាណផ្ទៃដីនិងរយៈពេលនៃការស្នើសុំរក្សាទុកអាជ្ញាបណ្ណស្វែងរុករក។

កាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាត្រូវតម្រូវដោយឡែកសម្រាប់អាជ្ញាបណ្ណស្វែងរុករកមួយជាក់លាក់និងមិនអនុញ្ញាតឱ្យមានការគិតគូររួមបញ្ចូលគ្នាដោយអាជ្ញាបណ្ណផ្សេងគ្នាទេ។

**មាត្រា៣៦ ._**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកអាចស្នើទៅរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដើម្បីសុំការលើកលែងកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាមួយផ្នែកឬទាំងស្រុង នៃឆ្នាំណាមួយដូចមានចែងក្នុងមាត្រា៣៥នៃអនុក្រឹត្យនេះដោយផ្អែកលើហេតុផលណាមួយដូចខាងក្រោមៈ

- ដែនអាជ្ញាបណ្ណទាំងមូលឬចំណែកណាមួយ កំពុងស្ថិតក្នុងជម្លោះ
- តម្រូវការរយៈពេលសម្រាប់ ពិនិត្យវាយតម្លៃឡើងវិញនូវលទ្ធផលនៃប្រតិបត្តិការធនធានរ៉ែ សរសេររបាយការណ៍ រៀបចំផែនការសកម្មភាព ឬធ្វើការស្វែងរកដើមទុនបន្ថែម

- តម្រូវការរយៈពេលសម្រាប់ធ្វើលទ្ធកម្ម
- ដែនអាជ្ញាបណ្ណពុំអាចចូលអនុវត្តប្រតិបត្តិការធនធានរ៉ែតាមការគ្រោងទុកបានដោយមានមូលហេតុសមស្រប
- តំបន់ជម្រករ៉ែត្រូវបានបម្រុងទុកសម្រាប់បន្តនិរន្តរភាពនៃប្រតិបត្តិការអាជីវកម្មធនធានរ៉ែបច្ចុប្បន្ន ឬគម្រោងអាជីវកម្មធនធានរ៉ែដែលបានស្នើឡើង
- សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ប៉ុន្តែពុំទាន់បានទទួលការអនុញ្ញាតផ្តល់អាជ្ញាបណ្ណជូននៅឡើយ
- មូលហេតុសមហេតុផលផ្សេងៗទៀតដែលសម្រេចដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ការលើកលែងកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមានេះ អាចអនុញ្ញាតយ៉ាងច្រើនបំផុតចំនួន ១២(ដប់ពីរ)ខែក្នុងរយៈពេលសុពលភាពសរុបនៃអាជ្ញាបណ្ណស្វែងរុករកប៉ុណ្ណោះ។

**មាត្រា៣៧ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកមានកាតព្វកិច្ចដូចខាងក្រោម៖

- អនុវត្តប្រតិបត្តិការធនធានរ៉ែតាមកម្មវិធីការងារដែលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងស្របតាមបទដ្ឋាន លក្ខខណ្ឌបច្ចេកទេស និងទម្លាប់អនុវត្តល្អប្រសើរនៃឧស្សាហកម្មនេះ
- អនុវត្តការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញនៅគ្រប់ទីតាំងនិងការដ្ឋានផ្សេងៗដែលមានផលប៉ះពាល់ឬខូចខាត បណ្តាលមកពីប្រតិបត្តិការធនធានរ៉ែ
- អនុវត្តផែនការគ្រប់គ្រងបរិស្ថានដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង
- បំពេញត្រឹមត្រូវនូវកាតព្វកិច្ចហិរញ្ញវត្ថុទាំងឡាយពាក់ព័ន្ធនឹងអាជ្ញាបណ្ណស្វែងរុករកដែលកំណត់ក្នុងអនុក្រឹត្យនេះ
- អនុវត្តតាមអនុក្រឹត្យនេះ លក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

**មាត្រា៣៨ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចព្យួរអាជ្ញាបណ្ណស្វែងរុករក ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណប្រព្រឹត្តល្មើសនឹងចំណុចណាមួយដូចខាងក្រោម៖

- ធ្វើការស្វែងរុករកក្នុងតំបន់ហាមឃាត់ដូចមានចែងក្នុងចំណុច ឆ ឬ ជ ឬ ឈ នៃមាត្រា៦នៃអនុក្រឹត្យនេះ
- មិនអនុវត្តកាតព្វកិច្ចចំណាយអប្បបរមាក្នុងប្រតិបត្តិការធនធានរ៉ែដូចមានចែងក្នុងមាត្រា៣៥នៃអនុក្រឹត្យនេះ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដូចមានចែងក្នុងមាត្រា៣៦នៃអនុក្រឹត្យនេះ
- មិនអនុវត្តកាតព្វកិច្ចកត់ត្រា ថែរក្សា និងផ្តល់ទិន្នន័យដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៤៩នៃអនុក្រឹត្យនេះ
- មិនផ្តល់របាយការណ៍ស្តីពីលទ្ធផលការងារនិងថវិកាចំណាយព្រមទាំងរបាយការណ៍បច្ចេកទេសស្តីពីការសិក្សារុករកធនធានរ៉ែដូចមានចែងក្នុងមាត្រា៥០នៃអនុក្រឹត្យនេះ

- មិនផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអំពីជម្រករ៉ែឬខនិជរ៉ែដូចមានចែងក្នុងមាត្រា៥១នៃអនុក្រឹត្យនេះ
- រារាំងឬមិនអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលចូលធ្វើការត្រួតពិនិត្យអធិការកិច្ចនៅក្នុងការដ្ឋានប្រតិបត្តិការធនធានរ៉ែ
- មិនផ្តល់របាយការណ៍សវនកម្មតាមការតម្រូវរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដូចមានចែងក្នុងមាត្រា៩៣នៃអនុក្រឹត្យនេះ
- មិនបង់ថ្លៃឈ្នួលផ្ទៃដីប្រចាំឆ្នាំនីមួយៗ ដូចមានចែងក្នុងកថាខណ្ឌទី២មាត្រា៩២នៃអនុក្រឹត្យនេះ
- មិនអនុវត្តកាតព្វកិច្ចណាមួយដូចមានចែងក្នុងចំណុចទី១ ឬទី២ ឬទី៣ ឬចំណុចទី៤នៃមាត្រា៣៧នៃអនុក្រឹត្យនេះ។

**មាត្រា៣៩ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសម្បទានិកដែលមានអាជ្ញាបណ្ណដែលប្រព្រឹត្តល្មើសនឹងចំណុចណាមួយដូចមានចែងក្នុងមាត្រា៣៨នៃអនុក្រឹត្យនេះឱ្យធ្វើការកែតម្រូវកំហុសនិងអនុវត្តតាមលក្ខខណ្ឌនានាដូចមានចែងនៅក្នុងលិខិតជូនដំណឹងក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃជូនដំណឹង។ ផុតរយៈពេលនេះប្រសិនបើសម្បទានិកដែលមានអាជ្ញាបណ្ណដែលប្រព្រឹត្តល្មើសនោះមិនបានបំពេញកាតព្វកិច្ចឬលក្ខខណ្ឌតម្រូវដូចមានបញ្ជាក់ក្នុងលិខិតជូនដំណឹងនោះទេ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចេញប្រកាសព្យួរអាជ្ញាបណ្ណស្វែងរុករក។

រយៈពេលនៃការព្យួរអាជ្ញាបណ្ណស្វែងរុករកមិនត្រូវលើសពី៦(ប្រាំមួយ)ខែឡើយ។ ផុតរយៈពេលនេះប្រសិនបើសម្បទានិកដែលមានអាជ្ញាបណ្ណដែលប្រព្រឹត្តល្មើសនោះនៅតែមិនអនុវត្តការកែតម្រូវសកម្មភាពប្រព្រឹត្តល្មើស រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវសម្រេចដកហូតអាជ្ញាបណ្ណស្វែងរុករកជាស្ថាពរ។

**មាត្រា៤០ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចដកហូតអាជ្ញាបណ្ណស្វែងរុករក ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណបានប្រព្រឹត្តល្មើសនឹងចំណុចណាមួយដូចខាងក្រោម៖

- ធ្វើប្រតិបត្តិការស្វែងរុករកក្នុងតំបន់ហាមឃាត់ដូចមានចែងក្នុងចំណុច ក ឬ ខ ឬ គ ឬ ឃ ឬ ង ឬ ច នៃមាត្រា៦នៃអនុក្រឹត្យនេះ
- ធ្វើប្រតិបត្តិការស្វែងរុករកក្នុងតំបន់ការពារធម្មជាតិឬតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ដោយគ្មានការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា១០នៃអនុក្រឹត្យនេះ
- ធ្វើការផ្ទេរសិទ្ធិ ឬកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ ឬដាក់អាជ្ញាបណ្ណជាវត្ថុធានាដោយពុំមានការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដូចមានចែងក្នុងមាត្រា៩០នៃអនុក្រឹត្យនេះ
- ជីកយកឬប្រមូលយកសំណាករ៉ែ ដី ថ្ម ខនិជរ៉ែ ទឹក ឬល្បាយផ្សេងៗក្នុងបរិមាណសរុបលើសពី១ ០០០(មួយពាន់)តោន សម្រាប់សិក្សាស្រាវជ្រាវ ពិសោធ និងធ្វើតេស្តសន្ធស្សន៍រ៉ែ ក្នុងរយៈពេលសរុបនៃសុពលភាពអាជ្ញាបណ្ណស្វែងរុករកដោយពុំមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដូចមានចែងក្នុងចំណុចទី២នៃមាត្រា៤៣នៃអនុក្រឹត្យនេះ

- ប្រព្រឹត្តល្មើសនឹងចំណុចណាមួយនៃមាត្រា៣៨នៃអនុក្រឹត្យនេះ ក្នុងអំឡុងពេលដែលអាជ្ញាបណ្ណស្វែងរុករកត្រូវបានព្យួរ
- មិនអនុវត្តតាមអនុក្រឹត្យនេះ លក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

**មាត្រា៤១ .-**

ក្នុងករណីដែលអាជ្ញាបណ្ណស្វែងរុករកត្រូវបានដកហូត សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវៈ

- ផ្តល់ឯកសារ ព័ត៌មាន ទិន្នន័យ និងសំណាកគំរូរ៉ែ ពាក់ព័ន្ធនឹងការស្វែងរុករករបស់ខ្លួនជូនមកក្រសួងរ៉ែនិងថាមពលក្នុងរយៈពេល៩០(កៅសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចដកហូតអាជ្ញាបណ្ណ
- ទូទាត់កាតព្វកិច្ចហិរញ្ញវត្ថុដែលនៅសេសសល់ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចដកហូតអាជ្ញាបណ្ណ
- រុះរើគ្រឿងចក្រ ឧបករណ៍ បរិក្ខារ ដែលបម្រើឱ្យការស្វែងរុករកក្នុងរយៈពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចដកហូតអាជ្ញាបណ្ណ។ ផុតរយៈពេលកំណត់នេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចចាត់ចែងឱ្យរុះរើគ្រឿងចក្រ ឧបករណ៍ បរិក្ខារ ដែលមិនបានរុះរើចេញពីដែនអាជ្ញាបណ្ណ ហើយសម្បទានិកដែលមានអាជ្ញាបណ្ណត្រូវទូទាត់រាល់ការចំណាយទាំងអស់លើការរុះរើ ការស្តារឡើងវិញនូវរាល់ផលប៉ះពាល់និងការខូចខាតនានាដែលបង្កដោយសកម្មភាពស្វែងរុករក។

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងឡាយដូចជា ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ទំនប់ទឹក ដែលបានសាងសង់ឡើងដោយសម្បទានិកដែលមានអាជ្ញាបណ្ណលើដីសាធារណៈឬដីឯកជន ដែលមានគោលដៅសម្រាប់ឱ្យសាធារណជនប្រើប្រាស់នឹងត្រូវចាត់ទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

**មាត្រា៤២ .-**

ក្នុងរយៈពេល៦(ប្រាំមួយ)ខែបន្ទាប់ពីអាជ្ញាបណ្ណស្វែងរុករកត្រូវបានបញ្ចប់ដោយអស់សុពលភាព ឬបន្ទាប់ពីការដកហូតចំណែកណាមួយនៃដែនអាជ្ញាបណ្ណ សម្បទានិកដែលមានអាជ្ញាបណ្ណឬបុគ្គលពាក់ព័ន្ធជាមួយនឹងសម្បទានិកដែលមានអាជ្ញាបណ្ណ មិនអាចស្នើសុំអាជ្ញាបណ្ណស្វែងរុករកសារជាថ្មីនៅក្នុងដែនអាជ្ញាបណ្ណដែលត្រូវបានបញ្ចប់ដោយអស់សុពលភាពឬចំណែកណាមួយនៃដែនអាជ្ញាបណ្ណដែលត្រូវបានដកហូតនោះបានឡើយ។

**មាត្រា៤៣ .-**

អនុវត្តតាមផែនការការងារដែលបានយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកមានសិទ្ធិដូចខាងក្រោមៈ

- ធ្វើប្រតិបត្តិការធនធានរ៉ែ ចេញ ចូល និងបោះទីតាំងនៅក្នុងតំបន់អាជ្ញាបណ្ណឬប្រើប្រាស់រថយន្ត គ្រឿងចក្រ និងឧបករណ៍សម្ភារៈបរិក្ខារផ្សេងៗ ដែលជាតម្រូវការសម្រាប់អនុវត្តប្រតិបត្តិការស្វែងរុករកធនធានរ៉ែនៅលើឬក្រោមដីនៅក្នុងតំបន់អាជ្ញាបណ្ណ

- ដឹកយកឬប្រមូលយកសំណាករ៉ែ ដី ថ្ម ខនិជរ៉ែ ទឹក ឬល្បាយផ្សេងៗ ក្នុងបរិមាណសរុបមិនលើសពី១ ០០០(មួយពាន់)តោន សម្រាប់សិក្សាស្រាវជ្រាវ ពិសោធ និងធ្វើតេស្តសន្ទស្សន៍រ៉ែក្នុងរយៈពេលសរុបនៃសុពលភាពអាជ្ញាបណ្ណស្វែងរុករក។ បរិមាណសំណាករ៉ែលើសពីនេះត្រូវស្នើសុំការអនុញ្ញាតបន្ថែមពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
- ប្រើប្រាស់ប្រភពទឹកធម្មជាតិសាធារណៈឬជីកអណ្តូងទឹកថ្មី ដើម្បីប្រើប្រាស់សម្រាប់សកម្មភាពប្រតិបត្តិការស្វែងរុករកធនធានរ៉ែ
- ប្រើប្រាស់ប្រភពទឹករបស់សហគមន៍ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ប្រើប្រាស់ផ្លូវឯកជនក្នុងករណីមានការព្រមព្រៀងគ្នាជាមុនជាមួយនឹងម្ចាស់ឬអ្នកកាន់កាប់គ្រប់គ្រងផ្លូវឯកជននោះ ដើម្បីចេញ ចូល ឆ្លងកាត់ឆ្ពោះទៅកាន់តំបន់ដែលខ្លួនបានទទួលអាជ្ញាបណ្ណ។

នីតិវិធីនៃការនាំចេញសំណាកគំរូរ៉ែ ដី ថ្ម ខនិជរ៉ែ ទឹក ឬល្បាយផ្សេងៗ សម្រាប់សិក្សាស្រាវជ្រាវ ពិសោធ និងធ្វើតេស្តសន្ទស្សន៍រ៉ែនៅក្រៅប្រទេសនឹងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៤៤.-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកអាចដាក់ពាក្យស្នើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកស្របតាមអនុក្រឹត្យនេះដោយផ្អែកលើមូលហេតុជាក់លាក់និងសមស្រប។

ពាក្យស្នើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកត្រូវបំពេញតាមទម្រង់បែបបទនិងព័ត៌មានតម្រូវ និងភ្ជាប់សក្ខីបត្របញ្ជាក់ពីការទូទាត់កម្រៃទទួលពាក្យស្នើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករក។

ប្រសិនបើសម្បទានិកដែលមានអាជ្ញាបណ្ណដែលបានដាក់ពាក្យស្នើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្នើសុំធ្វើការផ្ទេរសិទ្ធិ ហើយការផ្ទេរសិទ្ធិនេះត្រូវបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល នោះពាក្យស្នើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណដែលបានដាក់ពីមុននេះ ត្រូវបន្តក្រោមឈ្មោះរបស់អ្នកដែលបានទទួលសិទ្ធិបន្តឬស្របតាមសមាសភាពភាគហ៊ុនថ្មីរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ។

**មាត្រា៤៥.-**

សំណើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកលើតំបន់មួយផ្នែកឬទាំងមូលនៃតំបន់អាជ្ញាបណ្ណនឹងមិនត្រូវអនុញ្ញាតទេ លើកលែងតែតំបន់ស្នើសុំនោះមានសក្តានុពលសេដ្ឋកិច្ចជម្រករ៉ែដែលបានរកឃើញនិងការចាប់ផ្តើមអភិវឌ្ឍដើម្បីធ្វើអាជីវកម្មធនធានរ៉ែក្នុងពេលបច្ចុប្បន្នពុំទាន់អាចអនុវត្តបានដោយមូលហេតុណាមួយដូចខាងក្រោម៖

- ពុំទាន់មានលក្ខណៈសេដ្ឋកិច្ចគ្រប់គ្រាន់ឬដោយមានបញ្ហាទីផ្សារ ហើយជម្រករ៉ែត្រូវបានរំពឹងថានឹងមានលក្ខណៈសេដ្ឋកិច្ចគ្រប់គ្រាន់ឬអាចរកទីផ្សារបាននាពេលអនាគត
- តំបន់ជម្រករ៉ែត្រូវបានបម្រុងទុកសម្រាប់បន្តនិរន្តរភាពនៃប្រតិបត្តិការអាជីវកម្មធនធានរ៉ែបច្ចុប្បន្នឬសម្រាប់គម្រោងអាជីវកម្មធនធានរ៉ែដែលបានស្នើឡើង
- មានមូលហេតុត្រឹមត្រូវផ្នែកនយោបាយ ការតម្រូវចាំបាច់ដោយបញ្ហាបរិស្ថាននិងសង្គម ឬករណីប្រធានសក្តិដែលមិនអាចចាប់ផ្តើមអាជីវកម្មធនធានរ៉ែក្នុងពេលបច្ចុប្បន្នបាន។

ផ្ទៃដីនៃតំបន់ស្នើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកត្រូវផ្តុំជាតំបន់តែមួយនិងមានទំហំគ្រប់គ្រាន់ដើម្បីបម្រើឱ្យប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនាពេលអនាគត។

ក្នុងករណីដែលមានការអនុញ្ញាតឱ្យរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកលើផ្នែកណាមួយនៃដែនអាជ្ញាបណ្ណ ផ្នែកនោះត្រូវកាត់ចេញពីកម្មវត្ថុរយៈពេលនៃសុពលភាពរបស់អាជ្ញាបណ្ណស្វែងរុករកគិតចាប់ពីកាលបរិច្ឆេទនៃលិខិតអនុញ្ញាតឱ្យរក្សាទុកនោះ។

ក្នុងរយៈពេលរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករក សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវបន្តអនុវត្តកាតព្វកិច្ចហិរញ្ញវត្ថុនានាស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ។

ក្នុងករណីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ ឬដីឯកជន ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវធ្វើការពិគ្រោះយោបល់ជាមុនជាមួយនឹងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិង/ឬកម្មសិទ្ធិករនៃដីឯកជនមុននឹងសម្រេចលើសំណើសុំរក្សាទុករយៈពេលសុពលភាពអាជ្ញាបណ្ណ។

រយៈពេលសរុបនៃការអនុញ្ញាតឱ្យរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកមិនត្រូវលើសពី៥(ប្រាំ)ឆ្នាំ។

**មាត្រា៤៦ .-**

ក្នុងរយៈពេលរក្សាទុកសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករក រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកផ្តល់បច្ចុប្បន្នភាពនិងមូលហេតុដែលពុំទាន់អាចឬពុំបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ លើតំបន់អនុញ្ញាតរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករក។

ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកខកខានមិនបានផ្តល់មូលហេតុសមស្របជាលាយលក្ខណ៍អក្សរក្នុងរយៈពេលកំណត់ឬរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលកំណត់ថាមូលហេតុដែលផ្តល់ឱ្យដោយសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកមិនសមស្រប រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ លើតំបន់អនុញ្ញាតរក្សាទុកសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករកក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចេញលិខិតជូនដំណឹងពីការតម្រូវនេះ។

**មាត្រា៤៧ .-**

ក្នុងករណីដែលសំណើសុំរក្សាទុកសុពលភាពអាជ្ញាបណ្ណស្វែងរុករកត្រូវបានអនុញ្ញាតស្របតាមមាត្រា៤៥ខាងលើ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកអនុវត្តការងារចាំបាច់មួយចំនួនសម្រាប់រយៈពេលជាក់លាក់ណាមួយចំពោះតំបន់ដែលជាកម្មវត្ថុនៃការរក្សាទុកសុពលភាពអាជ្ញាបណ្ណដោយតម្រូវឱ្យសម្បទានិកនោះផ្តល់ជូនសេចក្តីព្រាងកម្មវិធីការងារចាំបាច់នោះជាមុនតាមទម្រង់កំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៤៨ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកនៅមានសុពលភាពមានសិទ្ធិស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនៅលើចំណែកផ្សេងៗនៃដែនអាជ្ញាបណ្ណស្វែងរុករកដោយអនុលោមតាមមាត្រា៥៣នៃអនុក្រឹត្យនេះ។

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកនៅមានសុពលភាព ហើយបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ប៉ុន្តែក្រោយមកអាជ្ញាបណ្ណស្វែងរុករកបានអស់សុពលភាព រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផ្តល់ការពន្យារសុពលភាពអាជ្ញាបណ្ណស្វែងរុករកនោះជាបន្តទៀតរហូតដល់មានការសម្រេចយល់ព្រមឬបដិសេធអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកធ្វើការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណក្រោយពេលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ហើយការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណនេះត្រូវបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល នោះពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែដែលបានដាក់ពីមុននេះត្រូវបន្តក្រោមឈ្មោះរបស់អ្នកដែលបានទទួលសិទ្ធិបន្ត។

**មាត្រា៤៩ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកត្រូវកត់ត្រានិងរក្សាទុកត្រឹមត្រូវ នូវរាល់ឯកសារកំណត់ត្រា សក្ខីបត្រ ទិន្នន័យ ព័ត៌មាន សំណាករ៉ែ និងលទ្ធផលវិភាគសំណាករ៉ែពាក់ព័ន្ធសកម្មភាពស្វែងរុករកធនធានរ៉ែនិងប្រតិបត្តិការផ្សេងៗក្រោមអាជ្ញាបណ្ណស្វែងរុករក ហើយត្រូវផ្តល់ឯកសារនិងកំណត់ត្រាទាំងនោះជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនៅពេលមានសំណើឱ្យផ្តល់ឬពេលមានការចុះពិនិត្យអធិការកិច្ចដោយមន្ត្រីមានសមត្ថកិច្ចដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

រាល់ទិន្នន័យ ព័ត៌មាន និងលទ្ធផលវិភាគសំណាករ៉ែ ដែលក្រសួងរ៉ែនិងថាមពលទទួលបានត្រូវរក្សាទុកជាការសម្ងាត់ក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណស្វែងរុករក។ រាល់ការប្រើប្រាស់ក្នុងគោលដៅសិក្សាស្រាវជ្រាវផ្សេងៗត្រូវមានការឯកភាពពីសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកជាម្ចាស់នោះ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវកំណត់នីតិវិធីសម្រាប់គ្រប់គ្រង ការរៀបចំទុកដាក់ ការរក្សាការសម្ងាត់ ការប្រើប្រាស់ទិន្នន័យព័ត៌មាន និងសំណាករ៉ែបម្រើដល់ការអភិវឌ្ឍវិស័យធនធានរ៉ែនៅកម្ពុជា។

**មាត្រា៥០ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកត្រូវរៀបចំនិងផ្តល់ជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនូវរបាយការណ៍ស្តីពីលទ្ធផលការងារនិងថវិកាចំណាយព្រមទាំងរបាយការណ៍បច្ចេកទេសស្តីពីការសិក្សារុករកធនធានរ៉ែដែលបានអនុវត្តជាក់ស្តែងប្រចាំឆ្នាំនីមួយៗ មុនដំណាច់ខែទីមួយនៃឆ្នាំបន្ទាប់ឬក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃក្រោយកាលបរិច្ឆេទបញ្ចប់អាជ្ញាបណ្ណស្វែងរុករក។ របាយការណ៍បច្ចេកទេសត្រូវរៀបចំដោយអ្នកជំនាញភូគព្ភសាស្ត្រឬធនធានរ៉ែ តាមទម្រង់និងបទដ្ឋានកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៥១ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអំពីជម្រករ៉ែឬខនិជរ៉ែ មានលក្ខណៈសេដ្ឋកិច្ចដែលបានរកឃើញក្នុងតំបន់អាជ្ញាបណ្ណស្វែងរុករកក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរក្រោយពីសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកបានកំណត់ទំហំសក្តានុពលជម្រករ៉ែរួចហើយ។

## ជំពូកទី៤
## អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

**មាត្រា៥២ .-**

ប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែរួមមាន សកម្មភាពស្វែងរុករកនិងជីកយករ៉ែ ដែលជម្រករ៉ែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយស្ថិតតែនៅក្នុងវង្វង់ព្រំដែនអាជ្ញាបណ្ណស្វែងរុករកព្រមទាំងការធ្វើអាជីវកម្មធនធានរ៉ែ ការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ។

**មាត្រា៥៣ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែលើតំបន់ដែលស្ថិតក្នុងវង្វង់ព្រំដែននៃអាជ្ញាបណ្ណស្វែងរុករកទៅក្រសួងរ៉ែនិងថាមពល។

ពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបំពេញតាមទម្រង់និងបែបបទ ដោយមានភ្ជាប់ឯកសារព័ត៌មានចាំបាច់ដូចខាងក្រោម៖

- សក្ខីបត្របញ្ជាក់អំពីការបង់កម្រៃសេវាទទួលពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- គម្រោងផែនការអភិវឌ្ឍការដ្ឋានរ៉ែ
- របាយការណ៍នៃការសិក្សាសមិទ្ធិលទ្ធភាពលម្អិតរៀបចំដោយអ្នកជំនាញដែលមានគុណវុឌ្ឍិពិតប្រាកដស្របតាមទម្រង់ បែបបទ និងមាតិកា កំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
- បណ្ណពន្ធប៉ាតង់ឆ្នាំចរន្ត
- របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន
- គម្រោងផែនការអភិវឌ្ឍសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធក្នុងតំបន់អាជីវកម្មធនធានរ៉ែ
- ផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ និង
- ឯកសារនិងព័ត៌មានចាំបាច់ផ្សេងៗទៀតតាមការចាំបាច់និងតាមស្ថានភាពជាក់ស្តែងនីមួយៗតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ទម្រង់និងបែបបទលម្អិត នៃពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៥៤ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកត្រូវធ្វើការសិក្សាឋានលេខា កំណត់ស្ថានភាពដី និងបោះបង្គោលសម្គាល់ព្រំប្រទល់តំបន់ស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ស្របតាមអនុក្រឹត្យនេះ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចាត់តាំងក្រុមការងារចុះពិនិត្យសិក្សាវាយតម្លៃនិងការបោះបង្គោលព្រំប្រទល់ដីនៃតំបន់ស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។ រាល់ចំណាយក្នុងការចុះពិនិត្យវាយតម្លៃនេះជាបន្ទុករបស់សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកដែលស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

សម្បទានិកស្នើសុំអាជ្ញាបណ្ណត្រូវចាត់តាំងឱ្យមានតំណាងរបស់ខ្លួនចូលរួមជាមួយនឹងក្រុមការងារដើម្បីធ្វើការពិនិត្យវាយតម្លៃតាមទីកន្លែងនិងពេលវេលាកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចបដិសេធពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្នុងករណី៖

- សម្បទានិកដែលមានអាជ្ញាបណ្ណខកខានពុំបានចាត់តំណាងចូលរួមជាមួយនឹងក្រុមការងារពិនិត្យវាយតម្លៃស្របតាមមាត្រានេះឬ
- សម្បទានិកដែលមានអាជ្ញាបណ្ណខកខានពុំបានអនុវត្តតាមការណែនាំណាមួយរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ក្នុងដំណើរការត្រួតពិនិត្យនិងវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែដែលបានស្នើ។

ក្នុងករណីដែនអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែផ្ដល់ជូនខុសពីតំបន់ដែលបានស្នើសុំ សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវធ្វើការបោះបង្គោលសម្គាល់ព្រំប្រទល់ដីឡើងវិញឱ្យបានឆាប់ក្នុងពេលវេលាសមស្រប។

**មាត្រា៥៥ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវពិនិត្យលើសំណើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាបណ្ណស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងអនុក្រឹត្យនេះ ទម្រង់ឯកសារនៃពាក្យស្នើសុំនិងធ្វើការវាយតម្លៃលទ្ធផលនៃការសិក្សាសក្ដានុពលសេដ្ឋកិច្ចធនធានរ៉ែក្នុងតំបន់ស្នើសុំព្រមទាំងទម្រង់ប្រតិបត្តិការធនធានរ៉ែដែលបានស្នើសុំ។

បន្ទាប់ពីបានពិនិត្យអំពីបច្ចេកទេស ហិរញ្ញវត្ថុ បរិស្ថាន សេដ្ឋកិច្ច និងសង្គមក្នុងគោលបំណងកំណត់លទ្ធភាពសេដ្ឋកិច្ចសង្គមនៃទម្រង់ប្រតិបត្តិការជីកយករ៉ែរួចហើយ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវ៖

ក- លើកសំណើសុំធ្វើអាជីវកម្មធនធានរ៉ែទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមនីតិវិធីជាធរមានដើម្បីទទួលបានការឯកភាពជាគោលការណ៍ជាមុន មុននឹងផ្ដល់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលឯកភាពនិងគាំទ្រលើគម្រោងអាជីវកម្មដែលបានស្នើសុំដោយសម្បទានិកដែលមានអាជ្ញាបណ្ណ។

ខ- ធ្វើការបដិសេធពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្នុងករណីលក្ខខណ្ឌណាមួយនៃការធ្វើអាជីវកម្មធនធានរ៉ែដែលកំណត់ដោយអនុក្រឹត្យនេះពុំត្រូវបានបំពេញ។ ក្នុងការវាយតម្លៃលទ្ធភាពសេដ្ឋកិច្ចនិងសង្គមនៃទម្រង់ប្រតិបត្តិការធនធានរ៉ែ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវជំរុញឱ្យមានការពិគ្រោះយោបល់និងការធ្វើអង្កេតសុរិធាន អសុរិធាន ជាមួយនឹងស្ថាប័នពាក់ព័ន្ធ អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគមន៍ដែលពាក់ព័ន្ធ និងស្របតាមគោលការណ៍អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់រាជរដ្ឋាភិបាល។

សម្បទានិកដែលមានអាជ្ញាបណ្ណដែលបានដាក់ពាក្យស្នើសុំត្រូវតម្កល់ច្បាប់ចម្លងនៃពាក្យស្នើសុំអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនៅមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលពាក់ព័ន្ធនឹងគោលបំណងត្រួតពិនិត្យនិងពិគ្រោះយោបល់ជាសាធារណៈ។

**មាត្រា៥៦ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកមួយអាចត្រូវបានផ្ដល់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែលើសពីមួយលើផ្ទៃដីចំណែកណាមួយឬច្រើន នៃផ្ទៃដីក្នុងដែនអាជ្ញាបណ្ណស្វែងរុករកដែលកំពុងមានសុពលភាពតាមការចាំបាច់និងតាមលក្ខខណ្ឌកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៥៧ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវដាក់ស្នើសុំការពិនិត្យសម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលលើផែនការផលិតកម្មប្រចាំឆ្នាំនៃឆ្នាំបន្ទាប់នៅក្នុងអំឡុងខែកញ្ញានៃឆ្នាំនីមួយៗ និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំក្នុងត្រីមាសនីមួយៗឬក្នុងរយៈពេលកំណត់ណាមួយ តាមការតម្រូវរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវអនុវត្តប្រតិបត្តិការធនធានរ៉ែស្របតាមផែនការផលិតកម្ម បច្ចេកទេសអាជីវកម្ម គំនូសប្លង់បច្ចេកទេស កម្មវិធីការងារ និងលក្ខខណ្ឌផ្សេងៗដែលកំណត់និងឯកភាពជាមុនពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងត្រូវអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្មព្រមទាំងច្បាប់និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន។

ក្នុងករណីមានប្រភេទរ៉ែថ្មីបន្ថែមក្នុងកម្មវត្ថុអាជីវកម្មឬការអនុវត្តជាក់ស្តែងតម្រូវឱ្យមានការប្រែប្រួលខ្លាំងខុសពីផែនការផលិតកម្ម បច្ចេកទេសអាជីវកម្ម គំនូសប្លង់បច្ចេកទេស កម្មវិធីការងារ និងលក្ខខណ្ឌផ្សេងៗ ដែលបានកំណត់និងឯកភាពពីមុនរួចហើយដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវស្នើសុំការឯកភាពជាថ្មីម្តងទៀត មុនពេលប្រភេទរ៉ែថ្មីនេះអាចធ្វើអាជីវកម្មបានឬការកែប្រែសំខាន់ៗនៃប្រតិបត្តិការធនធានរ៉ែអាចអនុវត្តទៅបាន។

តាមការស្នើសុំរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចអនុញ្ញាតឱ្យមានរយៈពេលដំណើរការផលិតកម្មសាកល្បងមួយក្នុងបរិមាណ រយៈពេល និងលក្ខខណ្ឌកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៥៨ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវអនុវត្តប្រតិបត្តិការធនធានរ៉ែដោយធានាឱ្យបរិមាណធនធានរ៉ែដែលមានក្នុងជម្រករ៉ែត្រូវបានផលិតបានច្រើនបំផុតជាអតិបរមាស្របតាមបទដ្ឋានលក្ខខណ្ឌបច្ចេកទេស ទម្លាប់អនុវត្តល្អប្រសើរនៃឧស្សាហកម្មនេះ និងគោលការណ៍ប្រសិទ្ធភាពសេដ្ឋកិច្ចព្រមទាំងចៀសវាងបានឬកាត់បន្ថយបានជាអតិបរមានូវរាល់ការខ្ជះខ្ជាយនិងបាត់បង់ធនធានរ៉ែ។

**មាត្រា៥៩ .-**

អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែដំបូងមានសុពលភាពមិនលើសពី២១(ម្ភៃមួយ)ឆ្នាំឬស្មើនឹងអាយុកាលនៃគម្រោងអាជីវកម្មធនធានរ៉ែ ក្នុងករណីអាយុកាលនៃគម្រោងអាជីវកម្មធនធានរ៉ែតិចជាង ២១(ម្ភៃមួយ)ឆ្នាំ។ សុពលភាពនេះអាចពន្យារបាន២(ពីរ)ដង តាមសំណើរបស់សម្បទានិកដែលមានអាជ្ញាបណ្ណដែលម្តងៗមានរយៈពេលមិនលើសពី១០(ដប់)ឆ្នាំ។ ក្នុងកាលៈទេសៈពិសេសអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែអាចពន្យារបានលើសពីការកំណត់ខាងលើ។

សុពលភាពរបស់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវរួមបញ្ចូលរយៈពេលរៀបចំ និងអភិវឌ្ឍផលិតកម្ម និងរយៈពេលបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ផលិតកម្មរ៉ែដំបូងត្រូវចាប់ផ្តើមក្នុងរយៈពេលមិនលើសពី៥(ប្រាំ)ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

**មាត្រា៦០ .-**

ពាក្យស្នើសុំពន្យារបន្តសុពលភាពអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវដាក់ឱ្យបានមុនកាលបរិច្ឆេទអាជ្ញាបណ្ណអស់សុពលភាព។ ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណខកខានឬពុំបានដាក់

ពាក្យស្នើសុំពន្យារបន្តសុពលភាពអាជ្ញាបណ្ណទាន់ពេលវេលាកំណត់នោះទេ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនិង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែពាក់ព័ន្ធ ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ ហើយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចេញប្រកាសជូនដំណឹងអំពីការបញ្ចប់នេះ។

ក្នុងករណីពុំមានការដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចាត់វិធានការចាំបាច់ដើម្បីបញ្ចប់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនិងដំណើរការបិទការដ្ឋានអាជីវកម្មធនធានរ៉ែ ឬរឹបអូស និងចាត់តាំងឱ្យមានការគ្រប់គ្រងដំណើរការការដ្ឋានអាជីវកម្មធនធានរ៉ែក្នុងនាមរបស់រដ្ឋវិញរហូតដល់មានការផ្តល់សម្បទានថ្មី។

ក្នុងករណីអាជ្ញាបណ្ណអស់សុពលភាព ប៉ុន្តែសម្បទានិកដែលមានអាជ្ញាបណ្ណបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពអាជ្ញាបណ្ណត្រឹមត្រូវតាមពេលកំណត់ អាជ្ញាបណ្ណនោះនៅតែមានសុពលភាពបន្តរហូតដល់មានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលលើពាក្យស្នើសុំ។

ក្នុងករណីបដិសេធការអនុញ្ញាតពន្យារបន្តសុពលភាពអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរ។

ក្រោយពេលបានដាក់ពាក្យស្នើសុំពន្យារសុពលភាពអាជ្ញាបណ្ណបន្តរួចហើយ ប្រសិនបើសម្បទានិកដែលមានអាជ្ញាបណ្ណធ្វើការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ ពាក្យស្នើសុំពន្យារបន្តសុពលភាពនៃអាជ្ញាបណ្ណដែលបានដាក់ពីមុនត្រូវចាត់ទុកជាពាក្យស្នើសុំរបស់អ្នកដែលបានទទួលសិទ្ធិបន្ត។

**មាត្រា៦១ .-**

អនុវត្តតាមផែនការការងារដែលបានយល់ព្រមពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមានសិទ្ធិដូចខាងក្រោម៖

- ធ្វើប្រតិបត្តិការធនធានរ៉ែលើនិងក្រោមផ្ទៃដីក្នុងតំបន់កំណត់ក្នុងអាជ្ញាបណ្ណ
- ប្រើប្រាស់ប្រភពទឹកធម្មជាតិសាធារណៈឬជីកអណ្តូងទឹកថ្មី ដើម្បីប្រើប្រាស់សម្រាប់សកម្មភាពប្រតិបត្តិការឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- ប្រើប្រាស់ប្រភពទឹករបស់សហគមន៍ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ប្រើប្រាស់ផ្លូវឯកជនក្នុងករណីមានការព្រមព្រៀងគ្នាជាមុនជាមួយម្ចាស់ឬអ្នកកាន់កាប់គ្រប់គ្រងផ្លូវឯកជននោះដើម្បីចេញ ចូល ឆ្លងកាត់ឆ្ពោះទៅកាន់តំបន់ដែលខ្លួនបានទទួលអាជ្ញាបណ្ណ
- ទទួលបានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ដីក្នុងដែនអាជ្ញាបណ្ណស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យនេះ និងលក្ខខណ្ឌនៃអាជ្ញាបណ្ណក្នុងរយៈពេលសុពលភាពរបស់អាជ្ញាបណ្ណនិង
- ទទួលបានសិទ្ធិជាម្ចាស់លើធនធានរ៉ែដែលបានពីប្រតិបត្តិការធនធានរ៉ែស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែទទួលបានសិទ្ធិផ្តាច់មុខក្នុងប្រតិបត្តិការធនធានរ៉ែនិងសិទ្ធិគ្រប់គ្រងប្រើប្រាស់ដីក្នុងដែនអាជ្ញាបណ្ណដែលផ្តល់ជូន។

**មាត្រា៦២ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមានសិទ្ធិប្រើប្រាស់ផ្លូវដឹកជញ្ជូនសាធារណៈដែលសាងសង់ដោយឯកជនឬសហគមន៍ ក្នុងឬក្រៅដែនអាជ្ញាបណ្ណសម្រាប់គោលដៅប្រតិបត្តិការ

ធនធានរ៉ែដោយត្រូវធានានិងចូលរួមក្នុងការជួសជុលថែទាំតាមសមាមាត្រនៃទំហំប្រើប្រាស់ជាក់ស្តែងស្រប តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

ភាគីពាក់ព័ន្ធទាំងអស់ត្រូវចាត់តាំងក្រុមការងារឬគណៈកម្មការសម្របសម្រួល និងកំណត់ចំណែក កម្រៃថែទាំប្រចាំឆ្នាំដែលត្រូវទូទាត់បង់ដោយគ្រប់ភាគីក្នុងគោលបំណងជួសជុលនិងថែទាំផ្លូវក្រោមការ សម្របសម្រួលរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តនានាជាធរមាន។

**មាត្រា៦៣ .-**

ក្រោយពីអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានបញ្ចប់ដោយអស់សុពលភាពឬត្រូវបាន ដកហូត សម្បទានិកដែលមានអាជ្ញាបណ្ណអាចត្រូវបានអនុញ្ញាតឱ្យចេញ ចូលទៅក្នុងដែនអាជ្ញាបណ្ណជាបន្ត ក្នុងរយៈពេលសមស្របមួយដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ដើម្បីអនុវត្តវិធានការបញ្ចប់ ការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញស្របតាមផែនការដែលបានឯកភាពដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិង ថាមពល។

**មាត្រា៦៤ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវរៀបចំនិងដាក់ស្នើសុំការពិនិត្យ សម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនូវឯកសារស្តីពីបទបញ្ជានិងវិធានការសុវត្ថិភាព ការងារដែលពាក់ព័ន្ធ នឹងប្រតិបត្តិការអាជីវកម្មធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណ មុនចាប់ផ្តើមដំណើរការអាជីវកម្មធនធានរ៉ែ។

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវធ្វើបច្ចុប្បន្នភាពនិងស្នើសុំការ ពិនិត្យសម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនូវឯកសារស្តីពីបទបញ្ជានិងវិធានការសុវត្ថិភាពការងារឡើងវិញ ជាទៀងទាត់រៀងរាល់២(ពីរ)ឆ្នាំម្តងឬក្នុងរយៈពេលកំណត់មួយតម្រូវដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៦៥ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមិនត្រូវធ្វើការសាងសង់សំណង់ឬ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែ បង្កើតការដ្ឋាន ទីតាំងស្តុករ៉ែ ទីតាំងស្តុកឬបញ្ចេញ ចោលសំណល់ពីការដ្ឋានរ៉ែ នៅក្រៅដែនអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែឡើយលើកលែងតែ មានការអនុញ្ញាតដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធតាមសំណើរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៦៦ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវធានាសម្របសម្រួលឱ្យការធ្វើ ទស្សនកិច្ចសិក្សាឬកម្មសិក្សានានា ដែលរៀបចំដោយស្ថាប័នផ្សេងៗតាមការឯកភាពពីរដ្ឋមន្ត្រីក្រសួងរ៉ែនិង ថាមពលក្នុងតំបន់ប្រតិបត្តិការធនធានរ៉ែរបស់ខ្លួនឬរៀបចំកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់សហគមន៍មូលដ្ឋាន ដើម្បីស្វែងយល់ពីប្រតិបត្តិការធនធានរ៉ែនៅតំបន់អាជ្ញាបណ្ណរបស់ខ្លួនអាចអនុវត្តបានដោយជោគជ័យ។

**មាត្រា៦៧ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវជូនដំណឹងជាមុនដោយភ្ជាប់ ផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ ដល់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលក្នុងរយៈពេលយ៉ាងតិច

៩០(កៅសិប)ថ្ងៃមុនការបិទឬបញ្ឈប់ការប្រើប្រាស់ជាអចិន្ត្រៃយ៍ នូវការដ្ឋានរ៉ែ ឬចំណែកណាមួយនៃការដ្ឋានរ៉ែ ឬហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែផ្តល់ព័ត៌មានជាក់លាក់បន្ថែមតាមការចាំបាច់ និង/ឬបញ្ចូលលក្ខខណ្ឌ និង/ឬកែតម្រូវផែនការឡើងវិញ និង/ឬកំណត់ទម្រង់បែបបទឱ្យអនុវត្តក្នុងការរៀបចំផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញនេះ។

**មាត្រា៦៨ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវធ្វើបច្ចុប្បន្នភាពនិងស្នើសុំការពិនិត្យសម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនូវគម្រោងផែនការបិទការដ្ឋានរ៉ែនិងគម្រោងស្តារបរិស្ថានឡើងវិញជាទៀងទាត់រៀងរាល់៣(បី)ឆ្នាំម្តងឬក្នុងរយៈពេលកំណត់មួយតម្រូវដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៦៩ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមិនត្រូវបង្ហូរ ឬបង្កឱ្យមានការបង្ហូរសំណល់រាវ ឬទឹកចេញពីការដ្ឋានរ៉ែ ទោះជាបានឬមិនបានឆ្លងកាត់ប្រព្រឹត្តិកម្មសម្អាតរួចហើយទៅក្នុងផ្លូវទឹកឬប្រភពទឹកធម្មជាតិរបស់ផ្លូវទឹកនៃតំបន់ក្រៅពីដែនអាជ្ញាបណ្ណដោយពុំមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឡើយ។

រាល់ការបង្ហូរសំណល់រាវឬទឹកចេញពីការដ្ឋានរ៉ែ សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវធានាអនុវត្តស្របតាមបទដ្ឋាននិងកម្រិតស្តង់ដាគុណភាព ដែលកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវចាត់វិធានការការពារនិងទប់ស្កាត់ការហូរច្រោះដី និងគំនរស្តុកសំណល់ផ្សេងៗចេញពីតំបន់អាជ្ញាបណ្ណទៅលើដីសហគមន៍ឬធ្វើឱ្យកកស្ទះផ្លូវទឹកប្រើប្រាស់របស់សហគមន៍។

ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអាចកំណត់ផ្លូវទឹកសាធារណៈណាមួយសម្រាប់ប្រើប្រាស់ក្នុងគោលបំណងអាជីវកម្មធនធានរ៉ែនិងតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែទូទាត់បង់សងការខូចខាតនិងជួសជុលថែទាំផ្លូវទឹកទាំងនោះ។

**មាត្រា៧០ .-**

ទោះជាមានមូលហេតុណាក៏ដោយ សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវទទួលខុសត្រូវចំពោះ៖

- រាល់ការខូចខាតឬខាតបង់ផ្សេងៗបង្កឡើងដោយការបំពុលពីការហូរចេញ ការបញ្ចេញចោល ឬការបង្ហូរចេញនៃសារធាតុផ្សេងៗពីការដ្ឋានរ៉ែឬផ្នែកណាមួយនៃប្រតិបត្តិការធនធានរ៉ែនិង
- រាល់ការចំណាយសមស្របផ្សេងៗក្នុងការចាត់វិធានការដោយភាគីពាក់ព័ន្ធដើម្បីបញ្ចៀសទប់ស្កាត់ឬកែតម្រូវ ការខូចខាតខាងលើព្រមទាំងការខូចខាតផ្សេងទៀតដែលបណ្តាលមកពីការចាត់វិធានការនេះ។

ក្នុងករណីមានភស្តុតាងច្បាស់លាស់បញ្ជាក់ថា គឺជាករណីប្រធានសក្តិដែលបង្កការខូចខាតដូចក្នុងកថាខណ្ឌខាងលើ ការទទួលខុសត្រូវអាចត្រូវបានកាត់បន្ថយសមស្របទៅតាមទំហំនិងសមាមាត្រនៃការបង្កឡើងដោយករណីប្រធានសក្តិនោះ។

**មាត្រា៧១ ._**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវផ្តល់ការធានាលើការអនុវត្តកាតព្វកិច្ចតាមកម្មវិធីការងារ ផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ ភាពអនុលោមតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណនិងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៧២ ._**

នៅពេលអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានបញ្ចប់ដោយអស់សុពលភាពឬចំណែកណាមួយនៃដែនអាជ្ញាបណ្ណត្រូវបានដកហូតឬប្រគល់សងវិញ សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវរុះរើយកចេញនូវសំណង់អគាររោងចក្រ គ្រឿងចក្រ ម៉ាស៊ីន ឧបករណ៍ បរិក្ខារ ឬអចលនទ្រព្យផ្សេងៗទៀតរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ ចេញពីដែនអាជ្ញាបណ្ណឬតំបន់ដែលត្រូវបានដកហូតឬប្រគល់សងវិញ ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃយ៉ាងយូរក្រោយកាលបរិច្ឆេទនៃការបញ្ចប់ ដកហូតឬប្រគល់សងវិញ។ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចកំណត់រយៈពេលមួយផ្សេងទៀតសម្រាប់រុះរើយកចេញនេះ។ សំណង់ឬហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធក្នុងការធានាសុវត្ថិភាពឬទ្រទ្រង់គ្រឹះសុវត្ថិភាពនៃការដ្ឋាននិងអណ្តូងរ៉ែផ្សេងៗមិនត្រូវអនុញ្ញាតឱ្យរុះរើចេញឡើយ លើកលែងតែមានការអនុញ្ញាតដោយឡែកពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ក្នុងករណីខកខានឬមិនបានរុះរើយកចេញដូចការកំណត់ខាងលើដោយគ្មានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីមូលហេតុសមស្របនៃការខកខានមិនបានរុះរើយកចេញនេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវប្រកាសដេញថ្លៃលក់ទ្រព្យសម្បត្តិទាំងអស់នោះនិងចាត់វិធានការឱ្យមានការរុះរើចេញតាមនីតិវិធីច្បាប់ជាធរមាន។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចកំណត់អំពីអចលនទ្រព្យណាខ្លះដែលគួររក្សាទុកជាបន្តក្នុងដែនអាជ្ញាបណ្ណក្រោយអាជ្ញាបណ្ណត្រូវបានបញ្ចប់។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចរចាឯកភាពជាមួយសម្បទានិកអំពីរយៈពេល របៀបនៃការកាន់កាប់ និងប្រើប្រាស់បន្ត និង/ឬលក្ខខណ្ឌនៃការជួលផ្សេងៗពាក់ព័ន្ធនឹងទ្រព្យសម្បត្តិទាំងនោះ។

**មាត្រា៧៣ ._**

ផលិតផលរ៉ែឬស្តុកល្បាយរ៉ែផ្សេងៗបន្សល់ទុកនៅលើដីឬក្រោមដី ក្នុងដែនអាជ្ញាបណ្ណក្រោយពេលអាជ្ញាបណ្ណត្រូវបានបញ្ចប់ត្រូវក្លាយជាកម្មសិទ្ធិរបស់រដ្ឋ។

ក្នុងករណីមានកិច្ចព្រមព្រៀងស្របច្បាប់ណាមួយរវាងសម្បទានិកដែលមានអាជ្ញាបណ្ណជាមួយនឹងកម្មសិទ្ធិករឬអ្នកកាន់កាប់ដីស្របច្បាប់ រាល់ការសម្រេចក្នុងមាត្រានេះត្រូវអនុវត្តស្របគ្នាតាមបញ្ញត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀងនោះ។

**មាត្រា៧៤ ._**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវផ្តល់របាយការណ៍ប្រតិបត្តិការលទ្ធផលការងារ និងចំណាយក្នុងប្រតិបត្តិការធនធានរ៉ែប្រចាំឆ្នាំ តាមទម្រង់កំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែ

និងថាមពលនៅមុនដំណាច់ត្រីមាសទីមួយនៃឆ្នាំបន្ទាប់ឬក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ បន្ទាប់ពីអាជ្ញាបណ្ណត្រូវបានបញ្ចប់។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណធ្វើរបាយការណ៍តាមទម្រង់និងកាលបរិច្ឆេទផ្សេងពីនេះ។

**មាត្រា៧៥ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវផ្តល់របាយការណ៍ផលិតកម្មនិងលក់ផលិតផលរ៉ែប្រចាំខែ តាមទម្រង់កំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃខែបន្ទាប់។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណធ្វើរបាយការណ៍តាមទម្រង់និងកាលបរិច្ឆេទផ្សេងពីនេះ។

**មាត្រា៧៦ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវទូទាត់ថ្លៃសួយសាររ៉ែស្របតាមអត្រា នីតិវិធី និងលក្ខខណ្ឌ កំណត់ក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាប្រសិទ្ធភាពនៃការប្រមូលសួយសាររ៉ែនិងកំណត់អំពីវិធីសាស្ត្រក្នុងការកំណត់តម្លៃរបស់ផលិតផលរ៉ែឬចំណាត់ថ្នាក់ផលិតផលរ៉ែសម្រាប់គោលបំណងគណនាសួយសាររ៉ែដោយផ្អែកលើកត្តាទីផ្សារជាក់ស្តែងក្នុងស្រុកនិង/ឬអន្តរជាតិ និងទម្លាប់អនុវត្តល្អប្រសើរជាអន្តរជាតិ។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចក្នុងការកំណត់ចំណាត់ប្រភេទផលិតផលរ៉ែនៃផលិតផលរ៉ែណាមួយឬការចាត់បញ្ចូលទៅក្នុងចំណាត់ថ្នាក់ផលិតផលរ៉ែណាមួយក្នុងគោលបំណងកំណត់អត្រាសួយសាររ៉ែនិងគណនាសួយសាររ៉ែ។

យន្តការគ្រប់គ្រងការប្រមូលសួយសាររ៉ែត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៧៧ .-**

ក្នុងករណីរកឃើញថាសួយសាររ៉ែឬចំណែកណាមួយនៃសួយសាររ៉ែ ពុំត្រូវបានបង់ ឬពុំត្រូវបានកំណត់វាយតម្លៃត្រឹមត្រូវ ឬពុំត្រូវបានគណនាត្រឹមត្រូវ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចធ្វើការកំណត់ប៉ាន់ស្មានតម្លៃសួយសាររ៉ែឡើងវិញ។ ការប៉ាន់ស្មានតម្លៃសួយសាររ៉ែឡើងវិញនេះត្រូវកំណត់ដោយផ្អែកលើព័ត៌មានផ្សេងៗដែលបានផ្តល់ជូនដោយសម្បទានិកដែលមានអាជ្ញាបណ្ណឬដែលអាចរកបានពីប្រភពផ្សេងៗទៀត។ ក្នុងករណីនេះរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សម្បទានិកដែលមានអាជ្ញាបណ្ណអំពី៖

- សេចក្តីស្នើការកំណត់ប៉ាន់ស្មានតម្លៃសួយសាររ៉ែឡើងវិញព្រមទាំងវិធីសាស្ត្រលម្អិតក្នុងការគណនាតម្លៃប៉ាន់ស្មានឡើងវិញនិង
- រយៈពេលកំណត់ដែលសម្បទានិកដែលមានអាជ្ញាបណ្ណត្រូវឆ្លើយតបឬលើកសំណើផ្សេងៗចំពោះការប៉ាន់ស្មានឡើងវិញនេះ។

ផុតរយៈពេលកំណត់ក្នុងសេចក្តីជូនដំណឹងអំពីការប៉ាន់ស្មានសួយសាររ៉ែឡើងវិញនិង/ឬបន្ទាប់ពីបានពិចារណាលើការឆ្លើយតបរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចកំណត់តម្លៃសួយសាររ៉ែដែលតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណទូទាត់ឬទូទាត់បន្ថែម។

**មាត្រា៧៨ .-**

នៅរាល់ពេលធ្វើការទូទាត់បង់ថ្លៃសួយសាររ៉ែ សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវផ្តល់សេចក្តីប្រកាសសួយសាររ៉ែតាមទម្រង់កំណត់ឬឯកភាព ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ក្នុងករណីយល់ឃើញថាសេចក្តីប្រកាសនោះធ្វើឡើងមិនត្រឹមត្រូវឬមិនមានភាពច្បាស់លាស់ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចចាត់តាំងមន្ត្រីមានសមត្ថកិច្ចធ្វើអធិការកិច្ចលើសេចក្តីប្រកាសសួយសាររ៉ែដែលរៀបចំឡើងដោយសម្បទានិកដែលមានអាជ្ញាបណ្ណដោយពុំចាំបាច់ជូនដំណឹងជាមុន។ ស្របតាមការចាត់តាំងនេះមន្ត្រីមានសមត្ថកិច្ចមានសិទ្ធិ៖

- ត្រួតពិនិត្យនិងធ្វើអធិការកិច្ច លើរាល់ប្រតិបត្តិការធនធានរ៉ែឬទីតាំងផ្សេងៗពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែ ស្តុកផលិតផលរ៉ែ ប្រតិបត្តិការគណនេយ្យ ឬទិន្នន័យផ្សេងៗនៃប្រតិបត្តិការធនធានរ៉ែពាក់ព័ន្ធ
- ត្រួតពិនិត្យនិងធ្វើអធិការកិច្ច លើរាល់ប្រតិបត្តិការធនធានរ៉ែឬទីតាំងផ្សេងទៀត ដែលមន្ត្រីមានសមត្ថកិច្ចយល់ថាអាចមានពាក់ព័ន្ធនឹងបទល្មើសឬភាពមិនប្រក្រតី ក្នុងការកំណត់សួយសាររ៉ែ
- តម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណឬតំណាង ផ្តល់ប៉េឬថតចម្លងរាល់ទិន្នន័យនិងឯកសារពាក់ព័ន្ធ និង
- តម្រូវឱ្យមានការធ្វើតេស្តសាកល្បងឬដំណើរការផលិតកម្ម ក្រោមការត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ចតាមការចាំបាច់។

ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណត្រូវបានកំណត់ថាបានប្រព្រឹត្តល្មើសនឹងមាត្រានេះ ហើយខកខានឬមិនបានទូទាត់បង់សួយសាររ៉ែបានត្រឹមត្រូវតាមការតម្រូវឱ្យបង់សួយសាររ៉ែដែលបានសម្រេចកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលនិងប្រាក់ពិន័យពាក់ព័ន្ធផ្សេងៗ បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលបានជូនដំណឹងពីការតម្រូវនេះក្នុងរយៈពេលកំណត់មួយ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចប្រកាសដកហូតអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនិងបញ្ចប់កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែដែលពាក់ព័ន្ធ។

**មាត្រា៧៩ .-**

ដើម្បីផ្តល់អំណះអំណាងលម្អិតអំពីការគណនាសួយសាររ៉ែ សម្បទានិកដែលមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវរក្សាទុកនិងថែទាំ ឱ្យបានត្រឹមត្រូវនូវរាល់កំណត់ត្រាទិន្នន័យប្រតិបត្តិការធនធានរ៉ែនិងផលិតកម្មរ៉ែ ក្នុងរយៈពេល៥(ប្រាំ)ឆ្នាំគិតពីកាលបរិច្ឆេទនៃការទូទាត់សួយសាររ៉ែឬកាលបរិច្ឆេទលក់ផលិតផលរ៉ែ ក្នុងករណីការលក់នេះត្រូវបានអនុវត្តក្រោយការបង់សួយសាររ៉ែ។

**មាត្រា៨០ .-**

ក្នុងអំឡុងពេលសុពលភាពអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ សម្បទានិកដែលមានអាជ្ញាបណ្ណអាចស្នើសុំបញ្ចប់អាជ្ញាបណ្ណទាំងស្រុងឬចំណែកណាមួយនៃផ្ទៃដីដែនអាជ្ញាបណ្ណជាលាយលក្ខណ៍

អក្សរមករដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលក្នុងរយៈពេលយ៉ាងតិច៩០(កៅសិប)ថ្ងៃមុនពេលបញ្ចប់ឬមុនពេលប្រគល់ចំណែកណាមួយនៃផ្ទៃដីសងវិញ។

ក្នុងករណីចំណែកណាមួយនៃផ្ទៃដីដែនអាជ្ញាបណ្ណត្រូវបានកាត់ចេញ ថ្លៃឈ្នួលដីនិងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតដែលពាក់ព័ន្ធនឹងត្រូវកាត់កងតាមសមាមាត្រគ្នា បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលចេញលិខិតបញ្ជាក់ការទទួលយល់ព្រមលើការកាត់ផ្ទៃដីចេញពីដែនអាជ្ញាបណ្ណនេះ។

ក្នុងករណីអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែជាកម្មវត្ថុដែលបានដាក់ជាវត្ថុធានា ការស្នើសុំការបញ្ចប់ឬកាត់ផ្ទៃដីតំបន់អាជ្ញាបណ្ណស្របតាមមាត្រានេះរបស់សម្បទានិកដែលមានអាជ្ញាបណ្ណ ត្រូវមានការឯកភាពពីភាគីពាក់ព័ន្ធជាមុន មុននឹងស្នើសុំមករដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

ការបញ្ចប់អាជ្ញាបណ្ណឬការកាត់ចំណែកណាមួយនៃផ្ទៃដីដែនអាជ្ញាបណ្ណស្របតាមមាត្រានេះ ពុំលើកលែងសម្បទានិកដែលមានអាជ្ញាបណ្ណឱ្យរួចពីកាតព្វកិច្ចនិងការទទួលខុសត្រូវណាមួយដែលមាននៅមុនពេលបញ្ចប់ឬមុនពេលកាត់ផ្ទៃដីនេះទេ។

**មាត្រា៨១ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចដកហូតអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែឬចំណែកណាមួយនៃផ្ទៃដីដែនអាជ្ញាបណ្ណក្នុងករណីណាមួយដូចខាងក្រោម៖

- កាតព្វកិច្ចហិរញ្ញវត្ថុនានា ឈ្នួលដី ឬសួយសាររ៉ែ មិនត្រូវបានអនុវត្តឬទូទាត់ត្រឹមត្រូវ ស្របតាមអនុក្រឹត្យនេះ
- សម្បទានិកដែលមានអាជ្ញាបណ្ណធ្វើការដឹកជញ្ជូនធនធានរ៉ែចេញពីដែនអាជ្ញាបណ្ណ ក្នុងករណីដែលធនធានរ៉ែនោះមិនទាន់បានបង់សួយសាររ៉ែឬគ្មានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
- សម្បទានិកដែលមានអាជ្ញាបណ្ណខកខានឬមិនបានផ្តល់កិច្ចសន្យាលក់ ទិន្នន័យ ឬឯកសារបញ្ជិកាគណនេយ្យ និងរបាយការណ៍តាមការតម្រូវដូចមានចែងក្នុងមាត្រា៧៤ ៧៥ ៧៧ ឬ៧៨ នៃអនុក្រឹត្យនេះ
- សម្បទានិកដែលមានអាជ្ញាបណ្ណបានរារាំងឬមិនអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលចូលធ្វើការត្រួតពិនិត្យអធិការកិច្ចនៅក្នុងការដ្ឋានប្រតិបត្តិការធនធានរ៉ែឬមិនអនុលោមតាមមាត្រា៩៣នៃអនុក្រឹត្យនេះ
- សម្បទានិកដែលមានអាជ្ញាបណ្ណមិនបំពេញកាតព្វកិច្ច លក្ខខណ្ឌ និង/ឬមិនអនុលោមតាមបទប្បញ្ញត្តិនានាដែលមានកំណត់ក្នុងអាជ្ញាបណ្ណនិង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ រួមទាំងបញ្ញត្តិដូចមានចែងក្នុងមាត្រា៨០ឬមាត្រា៨៧នៃអនុក្រឹត្យនេះ
- បង្កការប៉ះពាល់ធ្វើឱ្យខូចខាតរូបសណ្ឋានដើមរបស់ផ្ទៃដីធ្ងន់ធ្ងរខុសពីគម្រោងអភិវឌ្ឍនិងអាជីវកម្មធនធានរ៉ែ ឬពីកម្មវិធីនិងផែនការប្រតិបត្តិការធនធានរ៉ែ ដែលបានទទួលការឯកភាពជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
- មិនអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនិងវិធានស្តីពីសុខភាពនិងសុវត្ថិភាពអណ្តូងរ៉ែ
- សម្បទានិកដែលមានអាជ្ញាបណ្ណធ្វើការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ ឬដាក់អាជ្ញាបណ្ណជាវត្ថុធានាដោយពុំមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- មិនផ្តល់ទិន្នន័យសំណាកគំរូនិងលទ្ធផលវិភាគសិក្សាដែលបានអនុវត្តនិងបានទទួលពីប្រតិបត្តិការរបស់សម្បទានិកក្រោមអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ តាមការតម្រូវរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល
- មិនផ្តល់របាយការណ៍លម្អិតនិងបច្ចុប្បន្នភាពភ្លាមៗដល់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលចំពោះរបកគំហើញធនធានរ៉ែនិងការប្រែប្រួលសំខាន់ៗនៃសក្តានុពលសេដ្ឋកិច្ចរបស់ធនធានរ៉ែនៅក្នុងដែនអាជ្ញាបណ្ណ
- មិនធ្វើការពិនិត្យឡើងវិញនិងបច្ចុប្បន្នភាព ដោយទៀងទាត់នូវគម្រោងផែនការបិទការដ្ឋានរ៉ែនិងគម្រោងស្តារបរិស្ថានឡើងវិញស្របតាមរយៈពេលកំណត់ដូចមានចែងក្នុងអនុក្រឹត្យនេះ
- មិនអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថានដែលបានទទួលការឯកភាពពីក្រសួងបរិស្ថាន ហើយបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម
- មិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌនិងការតម្រូវកំណត់ដោយមាត្រា៧១នៃអនុក្រឹត្យនេះ ឬប្រព្រឹត្តល្មើសច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ឬអនុក្រឹត្យនេះ
- សម្បទានិកដែលមានអាជ្ញាបណ្ណមិនបានចាប់ផ្តើមផលិតកម្មរ៉ែដំបូងតាមការកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី២មាត្រា៥៩នៃអនុក្រឹត្យនេះ។

**មាត្រា៨២ .-**

ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណប្រព្រឹត្តល្មើសចំណុចណាមួយនៃមាត្រា៨១នៃអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចសម្រេចតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណធ្វើការបង់ពិន័យជាប្រាក់ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែនិងធ្វើការព្រមានជាលាយលក្ខណ៍អក្សរដល់សម្បទានិកដែលមានអាជ្ញាបណ្ណឱ្យធ្វើការកែតម្រូវចំណុចប្រព្រឹត្តល្មើសនោះក្នុងរយៈពេលកំណត់មួយ ប៉ុន្តែមិនត្រូវលើសពី៤៥(សែសិបប្រាំ)ថ្ងៃ។ ផុតរយៈពេលនេះ ប្រសិនបើសម្បទានិកដែលមានអាជ្ញាបណ្ណខកខានមិនបានទូទាត់ការពិន័យតាមការកំណត់និងមិនបានធ្វើការកែតម្រូវដូចមានបញ្ជាក់ក្នុងលិខិតព្រមាននេះទេ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនឹងត្រូវប្រកាសបញ្ចប់ឬដកហូតជាស្ថាពរ។

**មាត្រា៨៣ .-**

ក្រោយពីអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានបញ្ចប់ដោយអស់សុពលភាពឬដោយត្រូវបានដកហូត សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ទូទាត់កាតព្វកិច្ចហិរញ្ញវត្ថុដែលនៅសេសសល់ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបញ្ចប់ឬដកហូតអាជ្ញាបណ្ណ
- រុះរើគ្រឿងចក្រ ឧបករណ៍ បរិក្ខារ ដែលបម្រើឱ្យប្រតិបត្តិការធនធានរ៉ែក្នុងរយៈពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបញ្ចប់ឬដកហូតអាជ្ញាបណ្ណ។ ផុតរយៈពេលកំណត់នេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចចាត់ចែងឱ្យរុះរើគ្រឿងចក្រ ឧបករណ៍ បរិក្ខារ ដែលមិនបានរុះរើចេញពីដែនអាជ្ញាបណ្ណ ហើយសម្បទានិកដែលមានអាជ្ញាបណ្ណត្រូវទទួលបន្ទុកទូទាត់រាល់ការចំណាយទាំងអស់លើការរុះរើ ការស្តារឡើងវិញនូវរាល់ផលប៉ះពាល់ និងការខូចខាតនានាដែលបង្កដោយសកម្មភាពប្រតិបត្តិការធនធានរ៉ែ

- ស្តារឡើងវិញនូវរាល់ផលប៉ះពាល់ឬការខូចខាតនានាដែលបង្កដោយប្រតិបត្តិការធនធានរ៉ែស្រប តាមផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញនិង
- កាតព្វកិច្ចផ្សេងៗទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ និងអនុក្រឹត្យនេះ។

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងឡាយដូចជា ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ទំនប់ទឹក ដែលបាន សាងសង់ឡើងដោយសម្បទានិកដែលមានអាជ្ញាបណ្ណលើដីសាធារណៈឬដីឯកជនដែលមានគោលដៅ សម្រាប់ឱ្យសាធារណជនប្រើប្រាស់នឹងត្រូវចាត់ទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

**មាត្រា៨៤ .-**

ក្នុងរយៈពេល១២(ដប់ពីរ)ខែបន្ទាប់ពីអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានបញ្ចប់ដោយ អស់សុពលភាពឬបន្ទាប់ពីការដកហូតចំណែកណាមួយនៃដែនអាជ្ញាបណ្ណ សម្បទានិកដែលមានអាជ្ញាបណ្ណ ឬបុគ្គលពាក់ព័ន្ធជាមួយនឹងសម្បទានិកដែលមានអាជ្ញាបណ្ណ មិនអាចស្នើសុំអាជ្ញាបណ្ណស្វែងរុករកឬអាជ្ញាបណ្ណ ឧស្សាហកម្មអាជីវកម្មធនធានរ៉ែសារជាថ្មីនៅក្នុងដែនអាជ្ញាបណ្ណដែលត្រូវបានបញ្ចប់ដោយអស់សុពលភាព ឬចំណែកណាមួយនៃដែនអាជ្ញាបណ្ណដែលត្រូវបានដកហូតនោះបានឡើយ។

## ជំពូកទី៥
## បញ្ញត្តិរួមនៃអាជ្ញាបណ្ណស្វែងរុករកនិង អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

**មាត្រា៨៥ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណមានកាតព្វកិច្ចចូលរួមទទួលខុសត្រូវក្នុងការអភិវឌ្ឍសុខុមាលភាព របស់សហគមន៍មូលដ្ឋាន និងឃុំ សង្កាត់ពាក់ព័ន្ធ ក្នុងដែនដីប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន។

កាតព្វកិច្ចទទួលខុសត្រូវក្នុងការចូលរួមអភិវឌ្ឍសហគមន៍រួមមាន ការចូលរួមក្នុងសកម្មភាពអនុវត្ត គម្រោងផែនការអភិវឌ្ឍមូលដ្ឋានលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សុខុមាលភាពសាធារណៈ អប់រំ បណ្តុះ បណ្តាល និងការអភិវឌ្ឍសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធ។

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំឱ្យបានទៀងទាត់សម្រាប់ចូលរួម អភិវឌ្ឍសហគមន៍មូលដ្ឋាន។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវដឹកនាំនិងសម្របសម្រួលសម្បទានិកដែលមានអាជ្ញាបណ្ណនិង អាជ្ញាធរសាធារណៈពាក់ព័ន្ធលើការចាត់ចែងការចូលរួមអភិវឌ្ឍសហគមន៍នេះ ដើម្បីធានាភាពសមស្រប តាមផែនការអាទិភាពនៃការអភិវឌ្ឍមូលដ្ឋាននិងគោលការណ៍អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

ក្នុងករណីមានការបង្កើតមូលនិធិរ៉ែដើម្បីអភិវឌ្ឍសហគមន៍ យន្តការគ្រប់គ្រង និងនីតិវិធីក្នុងការ ប្រើប្រាស់មូលនិធិរ៉ែដើម្បីអភិវឌ្ឍសហគមន៍ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរ៉ែនិង ថាមពល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨៦ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវយកចិត្តទុកដាក់ផ្តល់អាទិភាពលើការប្រើប្រាស់ពលកម្ម សេវា និងទំនិញក្នុងស្រុកឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន និងស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវយកចិត្តទុកដាក់ជំរុញឱ្យមានការបណ្តុះបណ្តាល កសាងសមត្ថភាពជំនាញដល់និយោជិតកម្ពុជា ដើម្បីបំពេញបានតាមតម្រូវការសមត្ថភាពជំនាញនិងតួនាទីដឹកនាំក្នុងប្រតិបត្តិការធនធានរ៉ែ។

**មាត្រា៨៧ .-**

ក្នុងឆ្នាំនីមួយៗសម្បទានិកដែលមានអាជ្ញាបណ្ណមានកាតព្វកិច្ចចូលរួមជួយបណ្តុះបណ្តាលធនធានមនុស្សនិងកសាងសមត្ថភាពស្របតាមផែនការបណ្តុះបណ្តាលប្រចាំឆ្នាំដែលបានសម្រេចដោយរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៨៨ .-**

ក្នុងករណីអាជ្ញាបណ្ណត្រូវបានផ្តល់ឱ្យសម្បទានិកពីរឬច្រើន សម្បទានិកដែលមានអាជ្ញាបណ្ណទាំងនោះត្រូវទទួលខុសត្រូវរួមគ្នានិងដោយឡែកពីគ្នាចំពោះរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលលើរាល់កាតព្វកិច្ចនិងការទទួលខុសត្រូវទាំងអស់ក្នុងប្រតិបត្តិការធនធានរ៉ែស្របតាមអាជ្ញាបណ្ណដែលទទួលបាន។

សម្បទានិកដែលមានអាជ្ញាបណ្ណអាចចុះកិច្ចសន្យាម៉ៅការបន្តឬជួលជំនាញបច្ចេកទេសក្នុងការអនុវត្តប្រតិបត្តិការធនធានរ៉ែស្របតាមអាជ្ញាបណ្ណ។ ប្រតិបត្តិការធនធានរ៉ែនេះត្រូវចាត់ទុកថាបានអនុវត្តនិងទទួលខុសត្រូវដោយសម្បទានិកដែលមានអាជ្ញាបណ្ណ។

**មាត្រា៨៩ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវរៀបចំឱ្យមានទីស្នាក់ការអចិន្ត្រៃយ៍និងរចនាសម្ព័ន្ធគ្រប់គ្រងសមស្របនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលខុសត្រូវលើប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណដែលផ្តល់ជូន។

ក្នុងករណីចាំបាច់និងតាមទំហំនៃប្រតិបត្តិការធនធានរ៉ែ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចតម្រូវលក្ខខណ្ឌបន្ថែមអំពីរចនាសម្ព័ន្ធគ្រប់គ្រងនៅកម្ពុជានិងវិធានការចាំបាច់នានាក្នុងគោលដៅធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែនិងការការពារសុវត្ថិភាព បរិស្ថាន និងសង្គម។

**មាត្រា៩០ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវស្នើសុំការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលមុនពេល៖

- បង្កើតសម្ព័ន្ធអាជីវកម្ម ដែលកម្មវត្ថុអាជីវកម្មនៃការបង្កើតសម្ព័ន្ធអាជីវកម្មនោះពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណដែលផ្តល់ជូន
- ចុះកិច្ចព្រមព្រៀងផ្ទេរសិទ្ធិឬ

- ផ្ទេរផលប្រយោជន៍ពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណស្វែងរុករកនិង/ឬ អាជ្ញាបណ្ណ ឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

ការបង្កើតសម្ព័ន្ធអាជីវកម្ម ឬការចុះកិច្ចព្រមព្រៀងផ្ទេរសិទ្ធិ ឬការផ្ទេរផលប្រយោជន៍ណាមួយពាក់ព័ន្ធនឹងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណស្វែងរុករកនិង/ឬអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ អាចត្រូវបានអនុញ្ញាតតែក្នុងករណីដើម្បីបង្កើនលទ្ធភាព និងប្រសិទ្ធផលរបស់ប្រតិបត្តិការធនធានរ៉ែ និងមិនមានផលប៉ះពាល់អវិជ្ជមានចំពោះចំណូលរបស់រដ្ឋ។

សម្បទានិកដែលមានអាជ្ញាបណ្ណដែលធ្វើការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណត្រូវបំពេញបែបបទនានានិងកាតព្វកិច្ចហិរញ្ញវត្ថុស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

**មាត្រា៩១ ._**

ប្រភេទចំណាយដែលអនុញ្ញាតឱ្យយកមកគិតបញ្ចូលក្នុងចំណាយប្រតិបត្តិការអប្បបរមាស្របតាមអនុក្រឹត្យនេះមានដូចខាងក្រោម៖

- ចំណាយលើការសិក្សាអំពីផលប៉ះពាល់ផ្នែកបុរាណវិទ្យា មរតកវប្បធម៌និងប្រវត្តិសាស្ត្រ និងសហគមន៍មូលដ្ឋាននៅក្នុងដែនអាជ្ញាបណ្ណ
- ចំណាយលើការសិក្សាឋានលេខា ធរណីសាស្ត្រ បរិស្ថាន គម្របព្រៃ និងការប្រើប្រាស់ដីធ្លីក្នុងដែនអាជ្ញាបណ្ណ
- ចំណាយលើសកម្មភាពផ្សេងៗនៃប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណនៅក្នុងដែនអាជ្ញាបណ្ណ
- ចំណាយលើការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញនៅក្នុងដែនអាជ្ញាបណ្ណ
- ចំណាយលើការបង្កើតផ្លូវចេញ ចូលទៅក្នុងដែនអាជ្ញាបណ្ណ និងជម្រកធនធានរ៉ែ ប៉ុន្តែមិនត្រូវឱ្យលើសពី២០(ម្ភៃ)ភាគរយនៃចំនួនសរុបនៃកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមា
- ចំណាយលើការសិក្សាវិភាគសំណាកគំរូរ៉ែក្នុងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណ
- ចំណាយលើការសិក្សាភូគព្ភសាស្ត្រតាមរយៈការហោះហើរពីលើអាកាសត្រូវយកមកគិតតាមសមាមាត្រនៃទំហំផ្ទៃដីដែនអាជ្ញាបណ្ណដែលពាក់ព័ន្ធ។

មិនត្រូវបានអនុញ្ញាតឱ្យបញ្ចូលក្នុងចំណាយប្រតិបត្តិការអប្បបរមាដែលតម្រូវក្នុងអនុក្រឹត្យនេះទេនូវការចំណាយដូចខាងក្រោម៖

- ចំណាយលើការបោះបង្គោលព្រំនៃដែនអាជ្ញាបណ្ណ
- ចំណាយដើម្បីទទួលបានអាជ្ញាបណ្ណឬកែប្រែផលប្រយោជន៍ណាមួយពាក់ព័ន្ធនឹងអាជ្ញាបណ្ណ
- ចំណាយលើការសិក្សាស្រាវជ្រាវដែលមិនពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណ
- ចំណាយទូទាត់សងផលប៉ះពាល់ឬការខូចខាតនានាក្នុងប្រតិបត្តិការធនធានរ៉ែ។

**មាត្រា៩២ ._**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវរៀបចំឱ្យមានការចុះបញ្ជិកាអាជ្ញាបណ្ណធនធានរ៉ែនិងផ្សព្វផ្សាយជាសាធារណៈក្នុងគេហទំព័ររបស់ក្រសួងរ៉ែនិងថាមពល។ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវជំរុញឱ្យមាន

បច្ចុប្បន្នភាពជាប្រចាំនៃកំណត់ត្រាព័ត៌មានប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងអាជ្ញាបណ្ណនិងកំណត់នីតិវិធីតម្រូវឱ្យសម្បទានិកដែលមានអាជ្ញាបណ្ណផ្តល់ព័ត៌មានសម្រាប់កំណត់ត្រាចុះបញ្ជិកាអាជ្ញាបណ្ណនេះ។

សម្បទានិកដែលមានអាជ្ញាបណ្ណត្រូវបង់ចំណូលចូលថវិការដ្ឋនូវថ្លៃចុះបញ្ជី កម្រៃអាជ្ញាបណ្ណ ពាក្យសុំការពន្យារបន្ត ការផ្ទេរផ្សេងៗ និងថ្លៃឈ្នួលដីប្រចាំឆ្នាំដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩៣ .-**

សម្រាប់គោលបំណងផ្ទៀងផ្ទាត់ចំណាយប្រតិបត្តិការអប្បបរមារបស់សម្បទានិកដែលមានអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចៈ

- តម្រូវឱ្យសម្បទានិកផ្តល់ជូនរបាយការណ៍សវនកម្មលើរបាយការណ៍ចំណាយប្រតិបត្តិការដែលរៀបចំដោយសវនករដែលបានចុះបញ្ជីត្រឹមត្រូវតាមទម្រង់និងក្នុងរយៈពេលកំណត់ណាមួយដូចមានចែងក្នុងលិខិតជូនដំណឹងរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលឬ
- ចាត់តាំងបុគ្គលដែលមានគុណវុឌ្ឍិសមស្របឱ្យចុះធ្វើអធិការកិច្ចលើរបាយការណ៍ចំណាយប្រតិបត្តិការអប្បបរមា។

ក្នុងករណីមានភាពខុសគ្នារវាងចំណាយក្នុងរបាយការណ៍សវនកម្មឬរបាយការណ៍អធិការកិច្ច ជាមួយនឹងរបាយការណ៍ចំណាយប្រតិបត្តិការអប្បបរមាដែលបានផ្តល់ពីមុនដោយសម្បទានិកដែលមានអាជ្ញាបណ្ណ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចកំណត់យកលទ្ធផលនៃរបាយការណ៍សវនកម្មឬរបាយការណ៍អធិការកិច្ចធ្វើជាមូលដ្ឋាន សម្រាប់វាយតម្លៃភាពអនុលោមតាមកាតព្វកិច្ចចំណាយប្រតិបត្តិការអប្បបរមាស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា៩៤ .-**

សម្បទានិកដែលមានអាជ្ញាបណ្ណនិង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែដែលមានសុពលភាពមុនពេលអនុក្រឹត្យនេះចូលជាធរមានអាចដាក់លិខិតស្នើសុំរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដើម្បីពិនិត្យផ្តល់អាជ្ញាបណ្ណឡើងវិញនិង/ឬធ្វើការកែសម្រួលកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែទាំងនោះស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះក្នុងរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃយ៉ាងយូរក្រោយកាលបរិច្ឆេទចូលជាធរមាននៃអនុក្រឹត្យនេះ។

ផុតរយៈពេលខាងលើនេះ ក្នុងករណីសម្បទានិកដែលមានអាជ្ញាបណ្ណខកខានមិនបានដាក់លិខិតស្នើសុំរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដើម្បីពិនិត្យផ្តល់អាជ្ញាបណ្ណឡើងវិញនិង/ឬធ្វើការកែសម្រួលកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែទេនោះ ប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណត្រូវបន្តអនុវត្តស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃអាជ្ញាបណ្ណ និង/ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ដែលមានស្រាប់ទាំងនោះរហូតដល់អាជ្ញាបណ្ណនិង/ឬកិច្ចព្រមព្រៀងទាំងនោះត្រូវបានបញ្ចប់ឬដកហូត។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៩៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ